៤- គូកនអ្នកម្នាក់ មិនបានឈប់សម្រាកក្នុងថ្ងៃអាទិត្យ ចូរអ្នកពន្យល់ថា "ការមិនឈប់នេះ ជាការខុស" ។

៥- ចូរអ្នកអធិប្បាយអំពីមនុស្សមានរបៀប ។

៦- ក្នុងវេលារដូវប្រាំង ស្រមោចបានសន្សំស្បៀងអាហារទុកសម្រាប់រដូវរងា ។ វាទើបរស់នៅបានដោយស្រួលហើយថែមទាំងបានជួយអ្នករងទុក្ខលំបាកផង ។ ចូរអ្នកទាញឧទាហរណ៍មនុស្សណាមួយដែលមានមារយាទបែបនេះ ។

៧- ក្នុងឱកាសចូលឆ្នាំ អ្នកបានទទួលរង្វាន់ជាប្រាក់ ២០០ រៀល ។ តើប្រាក់នេះអ្នកនឹងចាត់ចែងធ្វើអ្វី? អ្នកត្រូវយកប្រាក់នេះទៅបំណាយក្នុងការឥតប្រយោជន៍ឬ ។ ជានឹងទិញកូនសៀវភៅសម្រាប់ចុះប្រាក់សំចៃមកត្រាទុក ។

៨- ចូរពន្យល់ពីមនុស្សប្រយ័ត្ន គឺមនុស្សរបេះសន្សំមិនឲ្យជំពាក់គេ មិនចង់ឲ្យមានការត្រួតត្រាពីអ្នកដទៃ (ម្ចាស់បំណុល) ទាំងមិនចង់ឲ្យថោកទាប ។

៩- ចូរគូររូបសណ្ឋានមនុស្សកំណាញ់ម្នាក់ ក្នុងការប្រព្រឹត្ត

នៅវេលាចូលទៅកាន់តុ ចូលទៅក្នុងជំនុំចំណោមបុណ្យ, នៅវេលាដែលមនុស្សនេះទទួលភ្ញៀវនៅផ្ទះខ្លួនផង នៅវេលាដែលមនុស្សនេះស្លាប់នៅលើគ្រែខ្លួនផង ។

១០- ចូរអធិប្បាយពីមនុស្សខ្ជះខ្ជាយ ។

១១- ក្មួយអ្នកម្នាក់បានធ្វើបាបឆ្កែ ។ ចូរអ្នកពន្យល់អំពីការកំណាចនឹងទោសនៃចរិយាវិបត្តិក្នុងអំពើរបស់វា ។

១២- ក្នុងសាយណ្ហសម័យមួយ មានក្មេងមួយហ្វូងនាំគ្នាធ្វើទារុណកម្ម (ធ្វើបាបកម្មដ៏អាក្រក់) ដល់សត្វឆ្កែ១ ។ បណ្ដាក្មេងទាំងនោះ មានម្នាក់ជាអ្នកត្រឹមត្រូវគ្រាន់បើជាងគេ ត្រឡប់មកដល់ផ្ទះវិញ បានគិតឃើញអំពើអាក្រក់នោះ ។ ចូរអ្នកបរិយាយក្នុងហេតុរឿងនេះដែលរលឹកបាន ។

(អស់ទាំងការសិតនឹងចិន្តាទាំងឡាយ ដែលមានអធិប្បាយបន្ទាប់ពីមេរៀនទីមួយ ៗ នឹងប្រើទៅជាការដាក់ធ្វើជាមេគំនិតសម្រាប់តែងសេចក្ដី ក៏ជាការស្រួលណាស់ ។ សូមលោកជាគ្រូទាំងឡាយ

ឲ្យសិស្សស្រង់ទុកធ្វើជាគោលក្នុងការតែងសេចក្តី ឬក្នុងការចោទ
ដណ្តឹងសួរតាម(ត្រូវការ) ។

# ជំពូក ៦

# Chapitre 6

# ករណីយកិច្ចរបស់មនុស្សចំពោះសង្គម

## Devoirs de l'homme envers la société

## ករណីយកិច្ចចំពោះយុត្តិធម៌

## Devoirs de Justice

### មេរៀនទី៣៧ ការចាំបាច់ និងវឌ្ឍនធម៌ សម្រាប់ជីវិតរបស់សង្គម

### Nécessité et avantage de la vie en société

១– មនុស្សយើងនឹងរស់នៅពេលតែឯកឯងពុំបានទេ, តោងតែមានការពាក់ទង៏ជួយគ្នាទៅវិញទៅមក ៗ ដូច្នេះ បើគ្មានការរួមរួមជាសង្គមទេ, នឹងរស់នៅដោយការចិញ្ចឹមជីវិតពុំបាន ៗ

អធិប្បាយថា : ទារកទើបនឹងកើត ដែលគេបោះបង់ចោលនឹងរស់នៅពុំបាន ដូចគ្នានឹងមនុស្សពេលម្នាក់ឯងនោះដែរ ៗ បើគ្មានការជួយធុរៈគ្នាទៅវិញទៅមក, ការរស់នៅក៏ពុំបានសម្រេច, ត្រូវតែព្រួតជួយ ឬប្រាស់គ្នាទៅវិញទៅមក គ្រប់តែការដែលធ្វើនោះ,

ដូចជាការភ្ជួររាស់ បុកបែងស្រែ កាត់ដេរសំលៀកបំពាក់ ឬសង់ផ្ទះ សម្បែងជាដើម ។ ម្យ៉ាងទៀតក្នុងសង្គម តោងតែមានមេធាវី (ស្មាក្តី) ដើម្បីការពារច្បាប់, ចៅក្រមពិនិត្យកាត់សេចក្តីត្រឹមត្រូវ, កងក្រ-វែល (ប៉ូលិស) ត្រួតត្រាខាងការប្រតិបត្តិច្បាប់, នៅសាលារៀន មានគ្រូសម្រាប់បង្ហាត់បង្រៀន, មានបណ្ឌិតជាអ្នកនិពន្ធសៀវភៅ សម្រាប់សិក្សានឹងបោះពុម្ព, មានសាសនាសម្រាប់ប្រតិបត្តិធ្វើយក មគ្គផល ។ល។ ដូច្នេះការរស់នៅក្នុងសង្គម ជាការសំខាន់ ។

២- មនុស្សនឹងត្រារស់នៅតែឯកឯងពុំបាន ។

អធិប្បាយថា: មនុស្សតោងស្វែងរកគ្នីគ្នាដើម្បីសេចក្តីសប្បាយ ផង ដើម្បីសំដែងទុក្ខរបស់ខ្លួនផង ។ មនុស្សត្រូវឲ្យគេស្រឡាញ់ រាប់រក បញ្ចេញសេចក្តីស្មោះស្ម័គ្ររកគ្នានឹងគ្នាទៅវិញទៅមក ។ មនុស្សដែលឥតគេរាប់ដូចជាមានទណ្ឌកម្មយ៉ាងធ្ងន់ តម្រូវទៅលើ គឺជាអ្នកជាប់ទោសឃុំឃាំងនៅដាច់តែឯង ។

៣- ប្រយោជន៍នៃការរស់របស់សង្គម អាចឲ្យមនុស្សបំពេញ ករណីយកិច្ចចំពោះគ្នាទៅវិញទៅមក ។

អធិប្បាយថា ៖ កិច្ចការក្នុងសង្គមនេះ ជាច្បាប់នាំឲ្យគោរពគ្នាទៅវិញទៅមក ក្នុងការរស់នៅ ក្នុងសេរី ក្នុងកេរ្តិ៍ឈ្មោះ ក្នុងយសស័ក្តិ ក្នុងរបស់ទ្រព្យ ។ កិច្ចការទាំងនេះជាករណីយ-កិច្ចដ៏យុត្តិធម៌ ដែលជាច្បាប់តកូនចៅទៅអនាគត ។ ម្យ៉ាងទៀត ការប្រួបប្រួមសង្គមនេះ ជាការនាំឲ្យមនុស្សបេះមានទឹកចិត្តប្រតិបត្តិក្នុងផ្លូវលោកនឹងផ្លូវធម៌ផង ធ្វើមនុស្សឲ្យមានសីលធម៌ ឲ្យមានចិត្តមេត្តាករុណា ព្រមទាំងឲ្យមានសតិសម្បជញ្ញៈផង ។ ខ្លួនយើងចង់បានសេចក្តីល្អយ៉ាងណា អ្នកដទៃក៏ចង់បានសេចក្តីល្អដូចគ្នាដែរ ។

៤– មនុស្សត្រូវតែនៅជាសង្គម មានកិច្ចធុរៈប្រាស្រ័យគ្នាទៅវិញទៅមក ។ កូនក្មេងត្រូវអាស្រ័យនឹងគ្រួសារ ។

អធិប្បាយថា ៖ មនុស្សយើងត្រូវបំពេញករណីយកិច្ចទៅវិញទៅមកចំពោះគ្នានឹងគ្នា ត្រូវស្រឡាញ់ពប់រកគ្នាដូចជាបងប្អូន ។

## ភាសិត-បិត្តា

ត្រូវតែជួយគ្នាទៅវិញទៅមក, នេះជាច្បាប់របស់មនុស្ស ។

មនុស្សទាំងអស់គ្នាត្រូវជួយធ្វើការឲ្យអ្នកម្នាក់, អ្នកម្នាក់ត្រូវជួយធ្វើការឲ្យគេទាំងអស់គ្នា ។

ការណាដែលគេត្រូវធ្វើ ហើយគេធ្វើបានល្អ ការនោះជាប្រយោជន៍ដល់សង្គម ។

កាលបើមនុស្សរួបរួមគ្នាជាសង្គម, ការខ្វះខ្វាយក៏បាត់ទៅឯង ។

* ចូរកុំប្រព្រឹត្តខុសនឹងនរណាឡើយ, ចូរធ្វើតែល្អនឹងមនុស្សទាំងឡាយ ដ្បិតមនុស្សទាំងនេះសឹងសុទ្ធតែជាមនុស្សជាតិ ។

* សូវស្លាប់ក្នុងច្បាប់ ជាជាងបានជ័យជំនះក្នុងអយុត្តិធម៌ ។

ចោទសួរ មនុស្សត្រូវនៅតែឯកឯងឬ? អ្វីខ្លះដែលជាវត្ថុធាតុសម្រាប់មនុស្ស? អ្វីខ្លះដែលជាគ្រឿងបញ្ញាសម្រាប់សង្គមដែលត្រូវការ ? កិច្ចការអ្វីខ្លះរបស់យើងចំពោះមនុស្សទាំងឡាយ ? ម្ដេចក៏មនុស្សយើងត្រូវធ្វើគុណសម្បត្តិរួបរួមគ្នា?

## ការអាន

## ភាតរភាពមនុស្សជាតិ

### La fraternité humaine

មនុស្សយើងនឹងនៅឯកឯងពុំបាន ជាហេតុនាំមកនូវសេចក្ដី

លំបាកនឹងទុក្ខវេទនា ។

ដើមឈើដែលដុះទោលដាច់ម្នាក់ឯង តែងតែត្រូវខ្យល់បោក បក់ជ្រុះសន្លឹកអស់ ទាំងមែកធាងក៏បាក់ខ្ចាត់ខ្ចាយ, តួដើមឈើនោះក៏ទោរទន់វែកវីក្រាបទៅរកផែនដី, ពុំបានលូតលាស់បំរើន ។ ដើមឈើទោលតែឯង ដែលគ្មានម្លប់ដទៃជួយការពារកំដៅព្រះអាទិត្យផង ច្រើនតែងាប់ ។

មនុស្សដែលនៅដាច់តែឯង គ្មានគ្នីគ្នាកំដរក្នុងសង្គម ក៏រស់នៅដោយលំបាកដូចគ្នានឹងដើមឈើនោះដែរ ។

ដូច្នេះ មនុស្សមិនត្រូវនៅតែម្នាក់ឯងឡើយ, គោងតែនៅរួមគ្នា មានសេចក្ដីប្រាស្រ័យទាក់ទងជួយគ្នាទៅវិញទៅមក ។ បើនៅតែឯងគិតតែខ្លួនម្នាក់ៗ មនុស្សនោះ នឹងជួបប្រទះទៅលើសេចក្ដីទុក្ខលំបាក នឹងឧបសគ្គពុំខាន ។

សត្វបក្សីចាប នឹងសត្វត្រចៀកកាំ ដែលជាសត្វខ្សោយគ្មានគ្រឿងសស្ត្រាវុធអ្វីការពារ តែបើមានសត្វបក្សីសាហាវយាយី, វាប្រួតគ្នាដេញកំចាត់ទៅបាន ។ ហេតុនេះបូរយកសត្វបក្សីនេះធ្វើជាគំរូ ៖

# ពន្យល់ពាក្យ

**ភាតរភាព** ន. ភាវៈនៃបងប្អូន, សេចក្ដីរាប់រកគ្នាដូចបងដូចប្អូន និយាយស្ដីរកគ្នាដោយភាតរភាព ។

**ដើមឈើទោល** ន.គុ. ដើមឈើដែលដុះតែឯងឆ្ងាយពីគេ ។

**រីក់** កិ. ទោរទន់ទៅរកដី, រីក់, ខ្យល់បោករីក់ ។

**ឧបសគ្គៈ** ន. គ្រឿងទើសទាក់. គ្រឿងជំពាស់ រារាំងដំណើរៈ ពីម្សិលមិញខ្ញុំមកមិនរួច ព្រោះមានឧបសគ្គ ។

**ត្រចៀកកាំ** ន. បក្សី ជាពួកសត្វបាប, សត្វមានកម្លាំងហើរយ៉ាងពូកែ អាចហើរឆ្លងសមុទ្របាន ។ សត្វនេះនៅក្នុងប្រទេសក្ដៅនឹងប្រទេសត្រជាក់ ៗ នៅស្រុកបារាំង តែដល់រដូវរងាសត្វត្រចៀកកាំថយពីទីនោះ មកនៅឯស្រុកក្ដៅវិញ; នៅស្រុកខ្មែរយើង តែដល់រដូវរំហើយរងា ទើបឃើញសត្វនេះត្រឡប់មកនៅវិញ ។

* * * *

## មេរៀនទី ៣៨ គោរពជីវិតអ្នកដទៃ

## Respect de la vie d'autrui.

១– យើងមិនត្រូវសម្លាប់នរណាទាំងអស់ ។ នេះជាបញ្ញត្តិរបស់សាស្ដា ។ លទ្ធិនេះសឹងមានស្ទើរតែក្នុងច្បាប់របស់ជនដែលមានអារ្យធម៌ (ស៊ីវិល័យ) ។

អធិប្បាយថា : ជីវិតជាគ្រឿងបូជារបស់មនុស្ស ។ អ្នកណាសម្លាប់ខ្លួនឯង, អ្នកនោះជាមនុស្សប្លែកពីគេ គឺមនុស្សខាតលក្ខណ៍, អកតញ្ញូ, មានបុក្យពោធោក ។ កំហុសនោះទឹងជួសជុលពុំបាន ។ មនុស្សបែបនេះ ក៏ចាត់ជាមនុស្សពុំមានបរិយាល្អ, ជាមនុស្សលង់ទៅដោយសេចក្ដីកំហឹងវង្វេង ។

២– ច្បាប់សម្រាប់លោក ហាមឃាត់មិនឲ្យសម្លាប់មនុស្សដូចគ្នា; តែមានលើកលែងខ្លះ គឺវៀរលែងតែគេធ្វើរំលោភមកលើយើងខ្លាំង ហើយជៀសវាងមិនកើត ដែលច្បាប់ហៅថា “ការតស៊ូក្នុងផ្លូវច្បាប់” **Légitime défense.**

អធិប្បាយថា : អ្នកជំលោះទាំងពីរនោះស្លាប់, មនុស្សដែលធ្វើ

គេមុននោះហើយលោកចាត់ថាមានកំហុស ដ្បិតខ្លួនមានបំណងនឹងធ្វើគេឲ្យវិនាសមុន, តែក្នុងការតស៊ូគ្នានោះ ក៏ត្រូវជៀសវាងកុំឲ្យដល់នូវសេចក្ដីស្លាប់ វៀរលែងតែនៅទីបំផុតជៀសវាងពុំរួច ។ ពេលនេះហើយដែលក្រសួងសមាគម ត្រូវដាក់ទណ្ឌកម្មជាទោសឧក្រិដ្ឋ ដល់អ្នកមានកំហុស ដើម្បីរារាំងកុំឲ្យមានប្រព្រឹត្តបទឧក្រិដ្ឋនេះតទៅ ។ ប្រទេសនីមួយៗ បើមានប្រទេសជិតខាងដទៃមករំលោភលើ ក៏ត្រូវតែតយុទ្ធ, តែការច្បាំង ក៏ជាការតយុទ្ធយ៉ាងសម្បើម ។

៣- ការតយុទ្ធម្នាក់នឹងម្នាក់តតួ ក៏ជាទម្លាប់នាំឲ្យអាប់យស ហើយជាចរិយាវិបត្តិ ។ ការតយុទ្ធតតួនេះជាការឥតអំពើ ពុំមានអ្នកផងសរសើរស្ងើចឡើយ ត្រឡប់ទៅជាមនុស្សព្រៃ ឥតដឹងខុសត្រូវ ។

៤-ដូច្នេះ ចូរយើងគោរពជីវិតមនុស្សផងគ្នា ។

អធិប្បាយថា: យើងមិនត្រូវសម្លាប់នរណាឡើយ, ត្រូវហាត់ទម្លាប់ជំនះនឹងកំហឹង នឹងសេចក្ដីវង្វើង កុំឲ្យវាមកគ្របសង្កត់បាន កុំបួលចិត្តប្រព្រឹត្តល្បែងណាដែលនាំឲ្យមានគ្រោះថ្នាក់ដល់ជីវិតឡើយ ។

# ភាសិតបិណ្ឌ

ការខូចខាតទាំងឡាយទឹងជួសជុលបាន; ឯជីវិតជួសជុលពុំបានឡើយ ។

ជីវិតជាគុណជាតដ៏ល្អ; ការសម្លាប់ខ្លួនឯងជាទោសឧក្រិដ្ឋយ៉ាងធំ ។

*ជីវិតមិនទៀង; សេចក្ដីស្លាប់ទៀង ។

ហេតុដែលកើតឡើងអំពីខ្លួន; ខ្លួនមិនមែនជាចៅក្រមល្អទេ ។

បើបុគ្គលម្នាក់ៗ មានច្បាប់នឹងជម្រះខ្លួនឯងបាន, សេចក្ដីយុត្តិធម៌មុខជាគ្មានទេ ។

មនុស្សមានសិទ្ធិរស់នៅ; ឯសង្គមក៏ត្រូវតែមានសិទ្ធិបិតថេរនៅដែរ ។

## ការហាត់បញ្ជាក់ឡើងវិញ

ចូរអធិប្បាយអំពីសេចក្ដីគោរពជីវិតអ្នកដទៃ ។ ហេតុដូចម្ដេចក៏បេះតែមានរឿងឧក្រិដ្ឋច្រើនឡើងៗ ? ដូចម្ដេចដែលហៅថាការ-

តស៊ូជាការចាំបាច់? ដូចម្ដេចដែលហៅថាប្រទេសជាតិមាតុភូមិ? អ្នកយល់ឃើញដូចម្ដេច ការតស៊ូគ្នាតត្វ? យើងនឹងសម្រេចបែបណានឹងទម្លាប់ដែលយើងត្រូវកាន់ ចំពោះការគោរពជីវិតមនុស្សផងគ្នា? ចូរអធិប្បាយកាសិតនឹងបន្ដាខ្លះអំពីការគោរពជីវិតមនុស្ស ។

* * * *

## មេរៀនទី ៣៩ ការគោរពចំពោះមនុស្សនិងសត្វ

វត្ថុនឹងសត្វ បើយើងពិចារណាគិតឲ្យមែនទែន មិនត្រូវឲ្យយើងគោរពសោះ គ្មានសិទ្ធិឲ្យយើងគោរពឡើយ ។ បានជាពោលដូច្នោះពីព្រោះសិទ្ធិតែងជាប់នៅនឹងករណីយកិច្ច ។ បើដូច្នេះ អ្នកណាគ្មានសិទ្ធិ អ្នកនោះមិនត្រូវបានទទួលការគោរពទេ ។

មនុស្សមានករណីយកិច្ចនឹងធ្វើឲ្យគោលបំណងខ្លួនឯងកើតឡើងមានសិទ្ធិតាំងនឹងផ្លូវដែកការ; ហេតុនេះបានជាមានអំណាចមានសិទ្ធិនឹងនៅទំនេរ ឬធ្វើអ្វីៗ ឬក៏ត្រូវប្រើប្រាស់របស់ទ្រព្យបាន; ប៉ុន្តែនឹងធ្វើដូច្នោះបាន លុះត្រាតែទ្រព្យអស់នោះជារបស់ខ្លួន ។

ចំណែកឯសត្វ ទឹងវត្ថុនានាដែលជារបស់ឥតវិញ្ញាណវិញ យើងគ្មានករណីយកិច្ចនឹងគោរពទេ ។ ពាល់តែមានបារិកពីរប្រការដូចពោលខាងក្រោម ទើបមានករណីយកិច្ចគោរព :

ក) វិចារណញាណ (raison) គឺមានបញ្ញាចេះដឹងខុសត្រូវ

ខ) មានសេរីភាព ពោលគឺអំណាចទទួលការខុសត្រូវ ។

សត្វនិងវត្ថុនានា គ្មានបារិកនេះសោះ ។ ដូច្នេះគ្មានសិទ្ធិនិងករ-ណីយកិច្ចទេ, ប៉ុន្តែដែលយើងត្រូវមានករណីយកិច្ចគោរពសត្វនិងវត្ថុនោះ, ពីព្រោះតែសត្វនិងវត្ថុជាប់ទាក់ទងនឹងមនុស្សដោយការបីបាច់ថែទាំ ។

តាមធម្មតាគេគោរពតែរបស់ឬវត្ថុណាដែលមានម្ចាស់, ប៉ុន្តែមានវត្ថុច្រើនទៀតដែលគ្មានម្ចាស់ ក៏ជារបស់ត្រូវយើងគោរពដែរ ពីព្រោះមានមនុស្សជាអ្នកបង្កើត ។ របស់សាធារណៈមានម្ចាស់ដែរ ។ តាមធម្មតា យើងច្រើនភ្លេច ច្រើនតែពោលថា របស់ឥតម្ចាស់, ម្ល៉ោះហើយមិនសូវអើពើនឹងថែទាំទេ, ច្រើនមើល

ឆាយថាគ្មានម្ចាស់ពិតប្រាកដ ។ តាមផ្លូវពិត វត្ថុទាំងនោះជាទ្រព្យមានម្ចាស់; ឯម្ចាស់ទ្រព្យនេះគឺអ្នកស្រុកទាំងអស់គ្នាដែលមានគំនិតរួមគ្នាបង្កើតឡើង គឺអ្នកស្រុកនេះឯង មានអំណាចប្រើប្រាស់បានគ្រប់ ៗ គ្នាទាំងអស់; ដូច្នេះយើងថាវត្ថុទាំងឡាយ ជារបស់សាធារណៈ មានម្ចាស់ពិតប្រាកដ ។

យើងមិនត្រូវបំផ្លាញឲ្យសោះ ពីព្រោះជាហេតុនាំឲ្យអន្តរាយដល់រាជការ បើទុកជាមិនអន្តរាយ ក៏នាំឲ្យអ្នកឯទៀតប្រើប្រាស់ផងមិនបាន ។

## ការអាន

## ជើងជប៉ុន

មនុស្សដែលមានអារ្យធម៌ (ស៊ីវិល័យ) មានពុទ្ធសាសនិកជនជាដើម ច្រើនប្រកាន់យកការរស់នៅរបស់មនុស្សជាតិ ថាជាវត្ថុដែលគេដំកល់ដំកើងទុកជាគ្រឿងបូជាដ៏ថ្លៃថ្លា ។

មានសេចក្ដីដំណាលថា មានក្សត្រមួយអង្គជាតិជប៉ុន ទ្រង់ប្រមូល

មកទូវជើងបុកណាយ៉ាងល្អ ធ្វើពីដីពកសាខៀន ជាជើងដែលគេទើបនឹងរកឃើញពីក្នុងប្រាសាទរបស់ទ្រង់ ហើយទ្រង់មិននឿយណាយនឹងការទតគ្រឿងនេះសោះ ដោយសេចក្ដីពេញព្រះហឫទ័យ ។

ថ្ងៃមួយ មានមហាតលិកដែលជាអ្នកបំរើ បានធ្វើឲ្យបែកជើងល្អនេះមួយដោយការធ្វេសប្រហែស; ក្សត្រនេះទ្រង់ព្រះពិរោធយ៉ាងខ្លាំង ហើយក៏បង្គាប់ឲ្យយកមនុស្សនោះទៅសម្លាប់ក្នុងវេលាព្រឹកស្អែកឡើង ។

នៅវេលាដែលនឹងសូត្រសាលក្រមកាត់ទោសសម្លាប់នោះ មានមនុស្សរបស់ទ្រង់ម្នាក់ ចូលទៅគាល់ទ្រង់ហើយនិយាយទូលថា "ទូលព្រះបង្គំជាខ្ញុំ មានធនធានយ៉ាងវិសេសសម្រាប់ជួសជុលជើងបែកនេះបាន, សូមទ្រង់នាំទូលព្រះបង្គំចូលទៅមន្ទីរដែលតាំងគ្រឿងលំអរបស់ទ្រង់" ។ ក្សត្រអង្គនេះ ទ្រង់បានយល់ព្រមតាមបុរសនេះសុំ ហើយឲ្យចូលមើលមន្ទីរតាំងនោះ, លុះចូលទៅដល់ ក៏បុរសនេះយកដំបងមួយវាយជើង ១៩ កំទេចជា១ពាន់បំណែក ។

ព្រះរាជានេះក៏លាន់ព្រះឱស្ឋថាៈ យី ! ហេតុដូចម្ដេចក៏ឯងធ្វើដូច្នេះ ?

បុរសនោះឆ្លើយឡើងថាៈ ទូលព្រះបង្គំធ្វើករណីយកិច្ចរបស់ទូលព្រះបង្គំ ហើយទូលទៅព្រះរាជាទៀតថាៈ ផើងនីមួយៗនេះតម្លៃស្មើនឹងជីវិតរបស់មនុស្សម្នាក់ៗឬ? សូមទ្រង់យកជីវិតទូលព្រះបង្គំទៅប្ដូរផ្លាស់ចុះ ។

ព្រះរាជា ទ្រង់ជ្រាបរឿងដែលបុរសនេះប្រដៅហើយ ក៏ពោលថា "អ្នកឯងនិយាយត្រូវ, ដ្បិតថាផើងលងទឹកមាសនេះ ពុំមែនមានតម្លៃស្មើនឹងជីវិតមនុស្សម្នាក់ទេ" ហើយទ្រង់លស់លាត្រាប្រណីដល់បាវព្រាវដែលធ្វើឲ្យបែកផើងហើយ និងបុរសដែលមានសេចក្ដីក្លាហាននោះ ។

## ពន្យល់ពាក្យ

ផើង ន. ភាជនៈធ្វើពីដីឬពីធាតុផ្សេងៗ សម្រាប់ដាក់ឥវ៉ាន់ ។

សាលក្រម ន. សំបុត្រសម្រេចសេចក្ដីដែលចៅក្រមប្រគល់ឲ្យគូក្ដីអ្នកឈ្នះកាន់រក្សាទុកជាសំគាល់; សាលក្រម ម.ជ.ក្រំ ។

លស់លាត្រាប្រណី លើកទោសពោល ។

* * * *

## មេរៀនទី ៤០ ការគោរពបំពោះការធ្វើ

បើយើងគោរពមនុស្ស, គួរយើងគោរពការដែលមនុស្សធ្វើផង។

តម្លៃនៃការធ្វើ.– យើងធ្វើការប្រយោជន៍ចិញ្ចឹមជីវិតពិតមែនហើយ, ប៉ុន្តែមានប្រយោជន៍ឯទៀតមានទំហំធំក្រៃលែងគឺ:

ក) ការដែលយើងធ្វើនាំឲ្យយើងដុះដាលចិត្តគំនិតកាន់តែធំកាន់តែខ្ពស់កាន់តែរីកធំឡើង ។ យើងធ្វើការជួយបង្កើតលោកទាំងមូល ។ ធម្មតាដែលមនុស្សកែប្រែឲ្យរឹតតែល្អឡើងៗ ក៏ដោយសារតែកិច្ចការរកឃើញរបស់អ្នកប្រាជ្ញនានា ។

គោរពការធ្វើរបៀបយ៉ាងណា ? យើងតោងគោរពការដែលយើងធ្វើ, យើងតោងគោរពការអ្នកឯទៀតផង គោរពរបស់ដែលជាស្នាដៃអ្នកទាំងនោះផង ។

ខ) យើងតុំត្រូវធ្វើរំខានដល់អ្នកដែលកំពុងធ្វើការ, ត្រូវទុកអ្នកធ្វើការនោះឲ្យបានស្រួល; ហើយបើយើងមិនធ្វើការទេ, គួរទុក

គេអ្នកធ្វើការឲ្យបានស្រួល ៗ

គ) ត្រូវគោរពរបស់ជាស្នាដៃអ្នកធ្វើការ មិនមែនគោរពដោយសារតែតម្លៃរបស់នោះដែលលក់ឬទិញមកថ្លៃទេ គឺត្រូវគិតដល់កំលាំងនឿយហត់របស់អ្នកធ្វើទេតើ ៗ

* * * *

## មេរៀនទី ៤១ គោរពសេរីភាពរបស់អ្នកដទៃ

**Respect de la liberté d'autrui.**



១- យើងត្រូវមានករណីយកិច្ចមិនគ្រាន់តែគោរពចំពោះជីវិតមនុស្សដូចគ្នានោះទេ, ត្រូវគោរពដល់សេរីភាពរបស់អ្នកដទៃផង;

សេរីភាពជាវត្ថុបូជាដ៏ថ្លៃថ្លា; បើគ្មានសេរីភាពនេះទេ, ជីវិតក៏គ្មានតម្លៃដែរ ។

អធិប្បាយថា : គេដកសេរីភាពពីមនុស្សណាម្នាក់ ព្រោះវាគ្មានវិចារណញ្ញាណ វាមិនដឹងថាខ្លួនវាធ្វើអ្វី ហើយវាទៅជាមហាទុច្ចរិត ដោយវាប្រព្រឹត្តធ្វើឲ្យគេភ័យ ។ គេដកសេរីភាពអំពីចោរកំណាចមានទោសធ្ងន់ក្រៃលែង ដោយវាប្រព្រឹត្តអំពើអាក្រក់ ។ ក្រៅអំពីពួកទាំងនេះ មនុស្សទាំងឡាយទោះបីជាត្លួន ឬជាមនុស្សខ្ចៅសក្រមាន ឬមានសិទ្ធិឬគ្មានសិទ្ធិក៏ដោយ ក៏ត្រូវតែមានអំណាចក្នុងការទៅមក ក្នុងការធ្វើនិងការឈប់សម្រាក ឬការប្រើពេលវេលាតាមសិទ្ធិរបស់ខ្លួន តាមចិត្តបានទាំងអស់ ឲ្យតែមនុស្សនោះមានកិរិយាល្អ មិនផ្ទុយនឹងបរិយាសាស្ត្ររបស់ច្បាប់ ។

២- ការកៀរគរមនុស្សយកមកធ្វើជាខ្ញុំកំដរបាវព្រាវ ដូចជាខ្ទេរជាន់ដើម ឬដូចជាជនជាតិខ្មៅ ដែលនៅប្រទេសអាហ្វ្រិក នោះជាការប៉ះពាល់ដល់សេរីភាពរបស់មនុស្ស ។

អធិប្បាយថា : ការកៀរគរមនុស្សយកមកធ្វើជាខ្ញុំកំដរ ពុំមែនជា

អំពើរបស់មនុស្សជាតិទេ, ដូចជានាយចៅហ្វាយណាមួយដែលមានអំណាចលើអាយុជីវិតរបស់មនុស្ស វាយដំពាត់ដាក់ ឬយកទៅលក់ដូរដូចជាវត្ថុសត្វធាតុ ។ ការកៀរគរទៅតាមអំពើអាក្រក់បែបនេះ កាន់តែបាត់បន្តិចម្តង ៗ ដោយសារព្រះពុទ្ធសាសនាដែលប្រដៅឲ្យមានមេត្តាករុណាដល់គ្នានឹងគ្នាដូចមានហាមជំនួញ ៥ ប្រការត្រង់សត្វណាជាដើម។១ទៀតនៅប្រទេសកម្ពុជាយើង រាជ-ការបានលើកលុបមិនឲ្យមានរបៀបនេះពីឆ្នាំ ១៨៨៤, ចំណែកខាងប្រទេសអឺរ៉ុបក៏លើកលុបដែរ : នៅអាណានិគមរបស់បារាំងសែសលុបពីឆ្នាំ ១៨៤៨, នៅអាណានិគមរបស់អាមេរិកលុបពីឆ្នាំ១៨៦៥, នៅអាណានិគមប្រទេសប្រេស៊ីលលុបពីឆ្នាំ ១៨៨៨ ។ .

៣– តមកនៅសង្គម ឬជនបទណាមួយ ក៏គង់នៅមានអំពើយង់ឃ្នងលបសម្លាប់ដើម្បីបន្ទំឲ្យចុះចូល ដែលជាទំនាស់ទង់សេរី-ភាពរបស់មនុស្ស ។

អធិប្បាយថា : នាយចៅហ្វាយបង្ខិតបង្ខំកូនឈ្នួលដែលគ្នានៅក្នុងអាសន្ន ឲ្យទទួលឈ្នួលថោកក្តី; ពុំនោះទេពួកកម្មករ កូនឈ្នួលឃើញចៅហ្វាយនាយកំពុងទាល់ក្រមត់គ្នាធ្វើកូដកម្ម ដើម្បីទង់តវ៉ា

ដំឡើងបៀវត្សរ៍ក្តី, មាតាបិតាបង្ខំកូនដែលនៅតូចឲ្យធ្វើការធ្ងន់ក្តី, មនុស្សមានទ្រព្យច្រើន ឬមនុស្សមានអំណាចរំលោភទៅលើអ្នកបោះឆ្នោត ឲ្យបោះឆ្នោតឲ្យខ្លួនក្តី ឬបង្ខិតបង្ខំឲ្យកាន់លទ្ធិសាសនាតាមខ្លួនក្តី; អំពើទាំងអស់នេះ សុទ្ធតែជាអាការរំលោភបំពានសេរី-ភាពរបស់អ្នកដទៃ ។

៤- ក្មេងទាំងឡាយត្រូវយល់ថា ការបង្ខិតបង្ខំក្នុងការឲ្យស្តាប់បង្គាប់របស់មាតាបិតា ពុំមែនជាការរំលោភឡើយ គឺជាការហ្វឹក-ហ្វឺនក្នុងការឲ្យស្តាប់បង្គាប់ ដើម្បីឲ្យបានល្អប៉ុណ្ណោះ ។

អធិប្បាយថា: វិចារណញ្ញាណរបស់កុមារទាំងនោះនៅខ្ចី មិនអាចទូន្មានខ្លួនឯងបាននៅឡើយ ត្រូវតែរៀនពត់ហាត់ឲ្យបានទម្លាប់ល្អ ត្រូវទទួលការជួយជ្រោមជ្រែង ការស្តីប្រដៅឲ្យបានទៅជាមនុស្សល្អឡើង; ការបង្ខិតបង្ខំដោយមេត្តាករុណាអំពីមាតាបិតាគ្រូអាចារ្យទាំងឡាយជាការដឹកនាំទៅរកផ្លូវល្អ គឺជាការហាត់រៀនខាងផ្លូវសេរីភាព ។

## ភាសិត_បិដ្ឋា

ការបំបាត់សេរីភាព ទុកដូចជាបំបាត់មនុស្ស; ទោសឧក្រិដ្ឋធំបំផុត បន្ទាប់ពីការពិឃាត ។ សេរីភាពជាមនុស្សធម៌ ។

ទាសភាពជាអយុត្តិធម៌. គឺជាទោសកំហុស ១ យ៉ាងធំ ។

ព្រះពុទ្ធសាសនាជាឫសគល់នាំមកនូវសេរីភាព ។

ចោទសួរ - ម្ដេចក៏មនុស្សត្រូវមានសេរីភាព? ដូចម្ដេចហៅថាមនុស្សខ្ញុំកញ្ជះគេ? សម័យនេះនៅប្រទេសខ្មែរនៅមានការកៀគរលក់មនុស្សដែរឬ? មាតាបិតាត្រូវបង្ខំកូនដែលនៅតូចឲ្យធ្វើការធ្ងន់ឬ? ការបង្ខិតបង្ខំគេឲ្យគេបោះឆ្នោតឲ្យក្ដី ឲ្យកាន់លទ្ធិសាសនាដែលខ្លួនត្រូវការក្ដី អស់ទាំងនេះទុកជាជាអ្វី?

## ការអាន

## សេរីភាព ក្នុងទាសភាព.

**La liberté dans l'esclavage**

មនុស្សដែលមានសេរីភាពពិតៗនោះ គឺមនុស្សដែលរួចផុតពីសេចក្ដីទុក្ខភ័យ នឹងសេចក្ដីលំបាក ទទួលស្ដាប់បង្គាប់តែសាស្ដា នឹងសម្បជញ្ញៈរបស់ខ្លួនប៉ុណ្ណោះ ។

សម័យមួយ មានពួកពុទ្ធបរិស័ទ ជើងវត្តដោតនាភម ឃុំរគាង ស្រុកកំពង់សៀម បានប្រជុំគ្នាធ្វើធម្មសាកច្ឆា ដើម្បីជជែកថា តើនរណាមួយមានប្រាជ្ញាវាងវៃ អាចដោះស្រាយបញ្ហាអំពីពាក្យហៅថា "សេរីភាពរបស់មនុស្ស" ។ បណ្ដាពួកពុទ្ធ-បរិស័ទដែលជួបជុំនេះ អ្នកខ្លះឆ្លើយថា "មានតែស្ដេចទេ ទើបមានអំណាចធំបំផុតលើរាស្ត្រ ទាំងជាស្ដេចឈ្នះបច្ចាមិត្តរបស់ខ្លួនផង" ។ ខ្លះឆ្លើយថា "មានតែអ្នកមានទ្រព្យច្រើនទេ ទើបគេអាចនឹងបំពេញកិច្ចតាមបំណងរបស់គេសព្វគ្រប់បាន" ។ បរិស័ទទី ៣ ឆ្លើយថា "មានតែមនុស្សលីវលាគមិនមានប្រពន្ធកូន ទើបគេអាចធ្វើដំណើរត្រាច់ចៅគ្រប់ជម្បូន អស់មួយជីវិតគេបាន មិនបាច់បង់ពន្ធដារអ្វីឡើយ" ។ បរិស័ទទី ៤ ឆ្លើយឡើងថា "ស្រេចតែមនុស្សព្រៃដែលចិញ្ចឹមជីវិត តែដោយការបរបាញ់សត្វនៅក្នុងព្រៃ ទើបឥតមាននៅក្រោមបង្គាប់នរណា គ្មានអ្នករាជការណាត្រួតត្រាបាន" ។ ខ្លះក៏ឆ្លើយថា "ស្រេចតែនឹងស្លាប់ ទើបផុតពីការត្រួតត្រា" ។

នៅទីបំផុត ទើបមានឧបាសកម្នាក់ឈ្មោះនៃ ឆ្លើយថា "អ្នកដែលរួចពីទាសភាព គឺមិនទៅធ្វើខ្ញុំគេ ទើបមានសេរីភាពពិត" ។ អ្នកទាំងអស់គ្នា ក៏យល់ព្រមថា ឧបាសកនៃឆ្លើយត្រឹមត្រូវ ទុកជាបានការ ។

ក្នុងរឿងនេះបានគតិថា: បើទុកជាប្រទេសឬនិគម ឬក៏អ្នកមានដំណែងយសសក្តិយ៉ាងណាក៏ដោយ ឲ្យតែមានសេរីភាពហើយ គេគោរពតែច្បាប់សាស្តានឹងសម្បជញ្ញៈរបស់គេប៉ុណ្ណោះ ។ នេះឯងហៅថា "សេរីភាពរបស់មនុស្ស" មិនមែនជាទាសភាពទេ ។

## ពន្យល់ពាក្យ

ពុទ្ធបរិស័ទ ន. អ្នកកាន់ព្រះពុទ្ធសាសនា ។

ធម្មសាកច្ឆា ន. ការសាកសួរគ្នាទៅវិញទៅមកតាមផ្លូវធម៌ផ្លូវច្បាប់, ប្រជុំគ្នាធ្វើធម្មសាកច្ឆាក្នុងធម៌ ។

មនុស្សលីវលោត ន. មនុស្សគ្មានប្ដីប្រពន្ធ, មនុស្សលីវ ។

ពន្ធដារ ន. ប្រាក់បង់ទៅឲ្យរាជការ: រាស្ត្រត្រូវបង់ពន្ធដារទៅឲ្យ

រាជការ ដើម្បីសាងប្រទេស ។

ខ្ញុំកញ្ជះ ន. ខ្ញុំកំដរ, ចុងភៅ, អ្នកបំរើ ឬអ្នកស៊ីឈ្នួលគេ; ស្រុកខ្មែរកាលជាន់ដើមច្រើនមានលោះមនុស្សយកមកធ្វើជាខ្ញុំកំដរៗ

* * * *

## មេរៀនទី ៤២ គោរព អធ្យាស្រ័យ - ជំនឿ - មតិ

## Tolérance - croyances - opinions

អធ្យាស្រ័យ គឺកិរិយាអត់ធន់ធ្មេចភ្នែកចំពោះការទាស់ចិត្តខ្លួន ដូចជាកំហុសគឺសេចក្ដីខុសឆ្គងរបស់អ្នកដទៃ ។ បើចង់បានសេចក្ដីសុខ, ត្រូវតែមានអធ្យាស្រ័យ ។ ម្យ៉ាងទៀតគេដឹងថា បើមិនអត់ធន់, នឹងនាំឲ្យមានសេចក្ដីទុក្ខកាន់តែចំរើនឡើងទៅទៀត ។ អធ្យាស្រ័យមានន័យខុសគ្នាពីការអត់ធ្មត់ (toléré) គឺយើងអត់ធ្មត់ទ្រាំធ្វើការអ្វី ៗ នីមួយ ៗ ដែលចៀសពុំរួច ដូចជានៅពេលក្ដៅឬពេលត្រជាក់ ឬយើងមានលំនៅក្បែរផ្លូវហើយអត់ធ្មត់នឹងសូរសន្ធឹកនៅទីផ្លូវ ។ល។ យើងត្រូវមានអធ្យាស្រ័យដល់ការខុសឆ្គងរបស់ជនដទៃ (រឿងម្ដាយនឹងកូន, គ្រូនឹងកូនសិស្ស, ចៅហ្វាយ

ទឹងអ្នកបំរើ) ។

អធ្យាស្រ័យគឺការអត់ឱនចំពោះអ្នកដទៃដែលមានគំនិតគិតខុសពីខ្លួន.យើង ។ ឧទាហរណ៍ៈ ត្រូវបណ្ដោយឲ្យបណ្ដាជនចូលកាន់សា-សនាតាមបំណងចិត្ត ចូលបក្ខពួកនយោបាយតាមចិត្តគិតឃើញៗ បើសិនជាឃើញខុស មិនត្រូវប្រើកំហ្លាំងឡើយ ត្រូវប្រើសម្រុសសម្រួលវិញ ។ ធ្វើដូច្នេះគឺជាផ្លូវស្រួលបញ្ចុះបញ្ចូលផង ។ មួយទៀតដោយគិតឃើញថា តែគោរពដល់មនុស្សហើយ បើនៅក្នុងលទ្ធិប្រជាធិបតេយ្យនោះ គេរិតតែត្រូវការរាប់អានចិត្តដែលមានអធ្យាស្រ័យនេះណាស់ទៅទៀត ។

អធ្យាស្រ័យរបស់រាជការៈ រាជការត្រូវមើលកុំឲ្យមានគំនិតផ្ទុយនឹងរាជការ ដែលជាហេតុនាំឲ្យអន្តរាយដល់រាជការ ដល់អ្នកស្រុក ។ ហេតុនេះបានជាមានក្រសួងឃោសនាការ សម្រាប់ផ្សាយដំណឹងទល់នឹងដំណឹងដែលរាជការយល់ថាមិនត្រឹមត្រូវ ហើយដែលជាហេតុនាំឲ្យកើតអន្តរាយផង គឺពន្យល់កុំឲ្យមានមនុស្សប្រព្រឹត្តល្មើសច្បាប់ កុំឲ្យមានធ្វើឃាតឬកុំឲ្យមានលួចប្លន់ជាដើម ។

រាជការត្រូវមានអធ្យាស្រ័យចំពោះការណាដែលប្រិតទៅហើយ បណ្ដាលឲ្យមានចលាចលកាន់តែច្រើនទៅទៀត ដូចយ៉ាងការកាន់សាសនាជាដើម, បើរាជការប្រិតប្រើអំណាចឥតគ្មានអត់ឱនអ៊ីបន្តិចបន្តួចសោះ ជាក់ពិតឲ្យពលរដ្ឋទាំងឡាយកាន់តែសាសនារាជការប៉ុណ្ណោះ; នេះជាហេតុនាំឲ្យកើតចលាចល ហៅថាចម្បាំងសាសនា ។

(នៅស្រុកខ្មែរ ក្នុងរាជ្យព្រះបាទទយ៉សោវត្ថិ ស្ដេចទ្រង់អនុញ្ញាតឲ្យប្រជារាស្ត្រ កាន់ព្រះពុទ្ធសាសនាជាប់រហូតមកដល់សព្វថ្ងៃ ។ ដូច្នេះគ្រប់សាលារៀនទាំងអស់ បើបញ្ចូលព្រះពុទ្ធសាសនាក្នុងកម្មវិធីរៀនផង ដើម្បីឲ្យសមតាមច្បាប់រដ្ឋធម្មនុញ្ញត្រង់មាត្រា ៨ ថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ នោះមិនជាទំនាស់នឹងអធ្យាស្រ័យនៃពលរដ្ឋខ្មែរទេ) ។

សេចក្ដីអធ្យាស្រ័យរបស់មនុស្សម្នាក់ៗ : យើងត្រូវមានអធ្យាស្រ័យក្នុងកាលដែលគេស្គាល់អធ្យាស្រ័យរបស់យើង គឺថាគេគោរពដល់សិទ្ធិនិងករណីយកិច្ចរបស់យើង ។ ដ្បិតថា យើងឲ្យគេ

គោរពសិទ្ធិនិងករណីយកិច្ចរបស់យើង ៗ មិនអាចបង្ខំឲ្យគេប្រព្រឹត្តតាមទំនើងចិត្តយើងឡើយ ។

មួយទៀត យើងត្រូវគោរពជំនឿរបស់ជនដទៃ ដូចជាជំនឿរបស់អ្នកកាន់សាសនាជាដើម ។ ដូចភាសិតខ្លះពោលថា "សាសនាណាក៏ដោយសឹងសុទ្ធតែល្អ" ។ ហេតុនេះ យើងត្រូវតែគោរពជំនឿព្រមទាំងគោរពមតិរបស់អ្នកដទៃផង ។

* * * *

## មេរៀនទី ៤៣ គោរពកេរ្តិ៍ឈ្មោះអ្នកដទៃ

## ក្លាវទោស, និន្ទា

## Respect de la réputation d'autrui
## Calomnie, Médisance

១- កិត្តិយសនិងកេរ្តិ៍ឈ្មោះ ជាវត្ថុដ៏ថ្លៃថ្លារុងរឿងដូចជាជីវិតនិងសេរីភាពដែរ ។ យើងត្រូវមានករណីយកិច្ចគោរពកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ឲ្យដូចជាយើងចង់ឲ្យគេគោរពកេរ្តិ៍ឈ្មោះរបស់យើងដែរ ។ ការក្លាវទោស ជាហេតុមានទម្ងន់ក្នុងករណីយកិច្ចរបស់មនុស្ស ។

អធិប្បាយថា : ការក្វារទោសអ្នកដទៃ ដែលគេគ្មានកំហុសទោសអ្វីសោះ ហើយពោលទោសៈគទៈទេ ៗ ហៅថា ពោលទោសគេដោយឥតសមហេតុសមផល; កំហុសនេះជួនណា នាំឲ្យអាប់កេរ្តិ៍ឈ្មោះរហូតដល់ទៅគ្រួសាររបស់គេផង ៗ អ្នកក្វារទោសគេបែបនេះនឹងមានទោសដល់ខ្លួន ៗ

២-និន្ទា មើលពីខាងក្រៅ ឃើញហាក់ដូចជាស្រាលជាងការក្វារទោសគេ, ប៉ុន្តែក៏ជាកំហុសអាក្រក់មួយដែរ ដោយការប្រណែនឫស្យាមិនមែនជាចរិតរបស់មនុស្សល្អសោះ ៗ

អធិប្បាយថា : និន្ទាគឺជាការប្រណែនគេ តិះដៀលគេ ស្វែងរកកំហុសពីគេ លាក់សេចក្តីល្អរបស់គេ និយាយតែទោសអាក្រក់របស់គេ ចូលចិត្តតែនិយាយដើមគេ; ទាំងនេះជាលក្ខណៈរបស់មនុស្សទុរជន ជាកិរិយាអាក្រក់ក្រៃលែង ៗ

៣-សេចក្តីប្រណែនឫស្យាក៏ដូចជាការនិន្ទាដែរ ៗ

អធិប្បាយថា : ដូចជាការធ្វើសំបុត្រប្លន់ឆ្នោតពីគេ បានសេចក្តីថាជាមនុស្សពោលពាក្យកុហកពីគេក៏បាន ៗ ចោរដែលលបលាក់

ខ្លួនក្នុងព្រៃ ពួនបាញ់សម្លាប់អ្នកដំណើរ លោកតាត់ចូលក្នុងការទិន្នាគុំគួនមួយយ៉ាងអាក្រក់ ៗ មនុស្សប្រុសខ្មោតនេះ បណ្ដាលឲ្យខូចជីវិតមនុស្សម្នាក់ ធ្វើឲ្យខូចដំណែងយសស័ក្តិ ថែមទាំងឲ្យវិនាសដល់គ្រួសារគេថែមទៀតផងក៏មាន, នោះលោកតាត់ជាមនុស្សអាក្រក់ជាងចោរនោះទៅទៀត ៗ

៤ – ចូរកុមារទាំងឡាយកុំធ្វើអំពើលាមកទាំងនេះ ដែលជាទម្លាប់អាក្រក់ទាំងពួកយើងក្ដី ទាំងអ្នកដទៃក្ដី; តោងប្រយ័ត្នមាត់ពាក្យសំដី ព្រោះបុរាណថា យើងពោលទោសពីគេ, ទោសនោះនឹងធ្លាក់មកលើយើងថ្ងៃណាមួយមិនខាន ៗ

## ការអាន

## អណ្ដាត

មានសេចក្ដីដំណាលថា សម័យថ្ងៃមួយ នៅផ្ទះគហបតីម្នាក់ឈ្មោះ ឃុនធាង គេត្រូវការលៀងភ្ញៀវ, បានប្រើបាវរបស់ខ្លួនឈ្មោះ អាជ័យ ឲ្យទៅរកទិញរបស់ដែលល្អ ៗ ដើម្បីយកមកធ្វើម្ហូបអាហារលៀងភ្ញៀវ ៗ អាជ័យ បានទិញសុទ្ធតែអណ្ដាតគោ

យកមកធ្វើម្ហូប ៗ លុះដល់ពេលស៊ីលៀង, អាជ័យលើកម្ហូបដែលធ្វើពីអណ្ដាតគោទៅឲ្យភ្ញៀវបរិភោគ ៗ កាលលើកដំបូង ពួកភ្ញៀវដែលបានបរិភោគអណ្ដាតគោពុំមានទាស់ចិត្តអ្វីទេ, លុះបន្ទាប់ៗ មកឃើញសុទ្ធតែអណ្ដាតគោដដែល ៗ ក៏មានចិត្តធុញទ្រាន់ ៗ ខណៈនោះ ម្ចាស់ក៏សួរអាជ័យថា "អញបានឲ្យឯងរកទិញតែរបស់ណាដែលល្អ ៗ យកមកធ្វើម្ហូប, ដូចម្ដេចបានជាឯងទិញតែអណ្ដាតគោយ៉ាងនេះ"? អាជ័យឆ្លើយថា អណ្ដាតគោនេះជាខ្សែរបស់ជីវិត ជាកូនសោរបស់វិទ្យាសាស្ត្រ ជាវត្ថុធាតុនៃសេចក្ដីពិតត្រង់ ទាំងជាវិចារណញ្ញាណផង ដោយអណ្ដាតនេះឯងហើយដែលគេអាចនឹងសង់ទីក្រុងមានការថែទាំរក្សាយ៉ាងម៉ឺងម៉ាត់បានផង គេអាចសិក្សាឲ្យបានចេះដឹងរហូតដល់ទៅការសោយរាជ្យបានផង ជាករណីយកិច្ចដំបូងជាងកិច្ចទាំងអស់ ៗ

ឃុនធានជាចៅហ្វាយ ដោយមានបំណងនឹងរកទោសបាវរបស់ខ្លួន ក៏បាននិយាយទៅអាជ័យថា "ថ្ងៃស្អែកនេះ ចូរឯងទិញរបស់ណាដែលអាក្រក់ជាងនេះ យកមកលៀងភ្ញៀវដដែលនោះ

ទៀត" ។ លុះព្រឹកឡើង អាជ័យក៏ទិញអណ្តាតគោដដែលទៀត យកមកលៀងគ្រូ ហើយក៏ពោលថា "មានតែអណ្តាតនេះឯង ដែលអាក្រក់ជាងគេបំផុតក្នុងលោកនេះ គឺជាមេសឹកសត្រូវគ្រប់យ៉ាង ជាមេនាំឲ្យបង្កើតរឿងផ្សេងៗ នាំឲ្យបាក់បែក បណ្តាលរហូតដល់ទៅទោសចំបាំងថែមទៀត; អណ្តាតនេះជាវត្ថុធាតុខាងសេចក្តីសុច-រិតពិតត្រង់ផង ខាងទុច្ចរិតផង; អណ្តាតនេះ អាចនឹងកំទេចបំផ្លាញទីក្រុងធំៗ ជាសឹកសត្រូវយ៉ាងសាហាវ" ។

នៅចុងបំផុត ពួកគ្រូក៏បាននិយាយថា "អាជ័យជាបាវបំរើនិយាយត្រូវ" ។

រឿងនេះបានគតិថា : ការអាក្រក់ល្អក៏មកពីអណ្តាត; ដូច្នេះកុមារទាំងឡាយគួរជាអ្នកប្រយ័ត្នក្នុងការនិយាយ កុំពោលក្លាវទោស, កុំប្រណៃទនិន្ទាគេឲ្យសោះ ព្រោះជាសឹកសត្រូវយ៉ាងធំ, គួរវៀរចាក កុំប្រព្រឹត្តអំពើលាមកទាំងឡាយនេះឡើយ ដូចពាក្យបុពណភាសិតថា :

— រលាស់អណ្តាតម្តងធ្វើឲ្យអន្តរាយជាងចាក់ពួយមួយលំពែងៗ

– ការនិន្ទាតូចតាចនាំមកនូវសេចក្តីវិនាស ដូចជាអណ្តាតភ្លើងតូច បណ្តាលឲ្យឆេះទៅជាភ្លើងធំបាន ។

–ការគ្មានទោសប្រៀបដូចជាប្រាក់កូន ។

ចោទសួរ– មនុស្សត្រូវរក្សាកេរ្តិ៍ឈ្មោះដូចជាអ្វី? ដូចម្តេចដែលហៅថាការទោស? ដូចម្តេចដែលហៅថានិន្ទា? ទោសអាក្រក់នេះក្មេងត្រូវប្រព្រឹត្តឬដូចម្តេច? ចូរទាញរឿងដែលសំដែងអំពីអណ្តាត គឺអាក្រក់ល្អក៏ព្រោះអណ្តាត ។

* * * *

## មេរៀនទី ៤៤ គោរពទ្រព្យជាអចលនវត្ថុរបស់អ្នកដទៃ

## **Respect des propriétés d'autrui**

១– មនុស្សទីមួយ ៗ ត្រូវមានករណីយកិច្ចមួយយ៉ាងជាទម្ងន់ដែលនឹងត្រូវគោរពទ្រព្យជាអចលនវត្ថុរបស់អ្នកដទៃ ព្រោះថាទ្រព្យនេះ ជារបស់បានមកពីការធ្វើ ។

អធិប្បាយថា: ទ្រព្យដែលមនុស្សរកបានហើយនេះ ម្ចាស់ទ្រព្យនឹងមានអំណាចថែទាំរក្សា មានអំណាចផ្លាស់ប្តូរបែកជាកេរ្តិ៍ឲ្យទៅកូនចៅគេ, ដ្បិតទ្រព្យទាំងនេះបានមកពីកម្លាំងប្រឹងប្រែងរកស៊ីញើសតាំងទឹក ៗ ដូច្នេះទ្រព្យទាំងនេះជារបស់បុជា ៗ គ្មាននរណា

ទីដណ្ដើមបាន ។ ការលួចរបស់អ្នកដទៃ គឺលួចយករបស់ដែលកើតអំពីកម្លាំងគេ ទុកដូចជាការរំបដាន់ទ្រព្យខ្លួនឯងផងដែរ ។ គ្រប់តែប្រទេស ទៅក៏តែងផ្ដន្ទាទោសជាធម្មតា ដល់មនុស្សប្រព្រឹត្តលួច ។ ហេតុដូច្នេះបានជាគេឲ្យឈ្មោះថាចោរ គឺថាមនុស្សនោះមានកំហុសទុកដូចជាដេរប្រមាថគេជាទម្ងន់ ។

២ _ មនុស្សលួចមានច្រើនបែបច្រើនយ៉ាង គឺ: ចោរលួច, ចោរប្លន់, ចោរឆក់ដណ្ដើម, ចោរឆរបោក; ចោរទាំងនេះក៏មិនមែនអស់ហើយតែត្រឹមប៉ុណ្ណោះទេ សូម្បីអស់ទាំងអ្នកលួចឯទៀតដែលលួចដោយប្រការផ្សេង ៗ ដូចជាលួចដោយថ្លឹងជញ្ជីង, ចងការប្រាក់យកការខុសច្បាប់, កែបន្លំទ្រព្យគេផ្ញើ, ស៊ីឈ្នួលគេមិនទៅធ្វើការឲ្យម្ចាស់, ម្ចាស់ឈ្នួលគឺនាយចៅហ្វាយចេញថ្លៃឈ្នួលឲ្យកូនឈ្នួលមិនគ្រប់តាមសន្យា, អ្នកទទួលរបស់ចោរទុក; អស់ទាំងនេះសឹងសុទ្ធតែឲ្យឈ្មោះថាចោរទាំងអស់ ។

៣. ការលួចជាការទុច្ចរិត ។ គុណសម្បត្តិជាសេចក្ដីសុចរិតរបស់មនុស្ស ។

អធិប្បាយថា : ការសងទៅវិញដោយគ្រប់ចំនួនជំពាក់, មិនមានកែបន្លំក្នុងការជួញលក់ដូរ, គោរពសេចក្ដីសន្យា, ធ្វើដោយហ្មត់ចត់នូវការងារណាដែលបានទទួលធ្វើ; ទាំងនេះ មនុស្សសុចរិតត្រូវគោរពឲ្យបានពេញលេញ ដើម្បីឲ្យមានកេរ្តិ៍ឈ្មោះពីរោះ ។

៤.- ហេតុដូច្នេះ ត្រូវតែគោរពចំពោះទ្រព្យអ្នកដទៃឲ្យណាស់ ។

អធិប្បាយថា : នៅសាលារៀន កុមារទាំងឡាយត្រូវទម្លាប់កុំយករបស់សម្បត្តិបន្តិចបន្តួច ដូចជាក្រដាស, ទឹកខ្មៅ, ស្លាបប៉ាកកា, គ្រឿងលេងជាដើម របស់គូកនគ្នាឯងឡើយ; ព្រោះជាកំហុសតូចអាចនាំឲ្យទៅជាធំ រហូតដល់យូរទៅបណ្ដាលឲ្យមានទោសឧក្រិដ្ឋផង ។ របស់ដែលរើសបានមកក្ដី ក៏តោងយកទៅសងឲ្យម្ចាស់គេវិញ ឬយកទៅប្រគល់ឲ្យអ្នករាជការ ។

ចោទសួរ— ដូចម្ដេចបានជាត្រូវគោរពទ្រព្យអ្នកដទៃ? ម្ដេចហៅថាលួច? មនុស្សលួចមានប៉ុន្មានយ៉ាង? សិស្សនៅសាលារៀនតោងធ្វើទម្លាប់ដូចម្ដេចខ្លះចំពោះទ្រព្យអ្នកដទៃ?

# ការអាន

## ទ្រព្យជាអបលនវត្ត

មនុស្សទាំងអស់នឹងឈប់ធ្វើការងារ ប្រសិនបើគ្មានសង្ឃឹមលើទ្រព្យដែលខ្លួនរកបានមកដោយព្យាយាមរបស់ខ្លួន ។

សត្វត្រីនេះដែលខ្ញុំខំព្យាយាម ឬចបានមកក្តី នំប៉័ងឬក្តាយដែលខ្ញុំប្រឹងរកបានមកដោយកម្លាំងក្តី តើរបស់ទាំងនេះគួរបានទៅនរណា ? គឺត្រូវតែបានមកខ្ញុំដែលជាអ្នកព្យាយាមធ្វើ ព្យាយាមរក ឬមួយនឹងថាត្រូវបានទៅមនុស្សកំជិល ដែលចេះតែដេកនៅវេលាដែលខ្ញុំកំពុងធ្វើការងារ ? មនុស្សទាំងអស់មុខជានឹងឆ្លើយយល់ព្រមថា នឹងត្រូវបានរបស់នេះមកខ្ញុំ, ដ្បិតថាខ្ញុំរស់នៅដោយការងារទាំងនេះ; ពុំនោះសោតទេ ក្នុងវេលាដែលខ្ញុំកំពុងបរិភោគបាយនៅមាត់ មានមនុស្សខ្ជិលស្ទុះមកបេះពីមាត់ខ្ញុំយក ឬមួយខ្លួនខ្ញុំស្ទុះទៅដណ្តើមយកនំបំណីពីមាត់អ្នកដទៃ ដូចជាគេស្ទុះមកដណ្តើមពីមាត់ខ្ញុំដែរ, នោះឃើញ ថាក្នុងលោកនេះ ការងារពិតប្រាកដនឹងសាបសូន្យ

ទីឋានរបស់មនុស្សលោក ដែលគេទុកដូចជាកើតជាទីយ៉ាងសម្បើម ក៏ក្លាយទៅជាកើតល្អបំផុតទៅវិញ; មនុស្សត្រឡប់ទៅជាសត្វតិរច្ឆាន ដូចខ្លា សិង្ហ ឆ្កែ ឆ្មា មិនទៅជាមនុស្សស៊ីវិល័យ ដូចជាអ្នកក្រុងភ្នំពេញ ឬក្រុងបាងកកឡើយ ។

ដូច្នេះ មនុស្សត្រូវតែប្រតិបត្តិការងាររបស់ខ្លួនរៀងៗខ្លួន មានរបរធ្វើស្រែចម្ការច្បារដំណាំ ដូញ្ញលក់ដូរ ។ល។ មិនត្រូវនៅទំនេរទេ ។ ដីនេះត្រូវយើងនាំគ្នាស្រឡាញ់ ត្រូវកាប់គាស់រើធ្វើជារបរដំណាំដែលឲ្យផលមកយ៉ាងធំ នាំឲ្យមានភោគទ្រព្យច្រើន ជាកេរ្តិ៍ដំណែលទុកឲ្យទៅកូនចៅផង ។

## ពន្យល់ពាក្យ

ទ្រព្យជាអចលនវត្ថុ ន. (សំ.ម. អចលន)ការមិនកម្រើក, មិនកម្រើក, មិនរំកើប; ការស្ងប់ ។ ទ្រព្យជាអចលនវត្ថុ គឺទ្រព្យណាដែលលើកមិនរួច ដូចជាដី ។

សិង្ហ ន. សត្វចតុប្បាទទ្រទ្រង់ទ្រាយប្រហែលនឹងសត្វខ្លាតែសម្បើម

ជាង, ពោមត្រង់កកំដុះវែងជាង ។

ក្ដើរដឹណែល ន. ទ្រព្យដំណែល ឬទ្រព្យសំបាច់របស់បុគ្គលស្លាប់ គឺមរតក: ទាមយកមរតក, ត្រូវបានមរតកជាដើម; សរសេរជា មរដកមកយូរហើយ ។

* * * *

## មេរៀនទី៤៥ គោរពសំដីដែលពោលហើយនឹងពាក្យសន្យា

### Respect de la parole donnée et des contrats

១ – មនុស្សសុចរិត មានតែសំដីមួយគឺជាសំដីទៀងទាត់, មនុស្សនោះតែពោលចេញទៅឲ្យគេហើយ គេនឹងទុកសំដីនោះជាសំដីត្រឹមត្រូវ ជាសំដីថ្លៃថ្នូរ ឲ្យសមជាអ្នកមានកិត្តិភាព ។

អធិប្បាយថា: កិច្ចការអ្វីនីមួយៗមុននឹងចុះកិច្ចសន្យា ត្រូវគិតគូរឲ្យហ្មត់ចត់សិនសឹមសម្រេចកិច្ចសន្យា, មិនត្រូវធ្វើកិច្ចការនោះស្រាលខ្ជីខ្ជាទេ ។

ការបំពានសំដីរបស់ខ្លួនដែលសន្យាឲ្យទៅគេហើយ នាំឲ្យខូចសេចក្ដីទុកចិត្តនៃមនុស្សទាំងពួង ដោយគេសម្គាល់ថាជាមនុស្សចិត្ត

មិនស្មោះត្រង់ ៗ ជីវិតរបស់សង្គមនឹងប្រព្រឹត្តទៅពុំកើត ដោយគ្មានសេចក្តីទុកចិត្តលើគ្នាទៅវិញទៅមក ៗ បានការលើកលែងខ្លះក្នុងកិច្ចសន្យាណាដែលពិនិត្យទៅឃើញថា មនុស្សដែលចុះសន្យានោះមានសតិស្មារតីពុំគ្រប់គ្រាន់ ៗ ។

២– កិច្ចសន្យាទីមួយៗ ត្រូវធ្វើឲ្យហ្មត់ចត់ ជាកត្តិភាពរវាងគ្នានឹងគ្នា គឺរវាងអ្នកដែលឲ្យបន្ទុក នឹងអ្នកដែលទទួលបន្ទុក; បើអ្នកទាំងពីរមិនបំពេញកិច្ចការតាមសន្យានោះទេ, ឃើញថាពុំមានបរិយាល្អ ហើយច្បាប់នឹងត្រូវទៅតាមទោសានុទោស ៗ

អធិប្បាយថា: ចៅហ្វាយនាយមិនត្រូវបណ្តេញបំបរបង់កូនឈ្នួលដោយឥតហេតុ ឬកូនឈ្នួលមិនត្រូវបោះបង់ចោលការងាររបស់ចៅហ្វាយនាយដោយឥតហេតុដែរ ៗ កាលណាមានលក្ខន្តិកៈទៅវិញទៅមកក្នុងកិច្ចសន្យា ត្រូវតែប្រតិបត្តិរៀងខ្លួន; បើពិនិត្យទៅឃើញថាពុំត្រឹមត្រូវតាមកិច្ចសន្យានោះទេ ត្រូវប្តឹងតវ៉ាដល់តុលាការ ៗ

៣– យើងមិនត្រូវចុះកិច្ចសន្យាដោយមិនបានគិតគូរឲ្យហ្មត់ចត់ជាមុននោះទេ; តែបើបានជាចុះកិច្ចសន្យាហើយ, ត្រូវប្រតិបត្តិ

កិច្ចសន្យានោះជាកត្តីភាព, ត្រូវយល់ថាមនុស្សសុចរិតគេមិនចាំបាច់ចុះកិច្ចសន្យាផងទេ គ្រាន់តែសំដីដែលគេថាក៏ទុកជាបានការ ។

សេចក្ដីសួរ — មនុស្សសុចរិតចេះគោរពពាក្យរបស់ខ្លួនដូចម្ដេច? និងទៅជាដូចម្ដេចទៅ ក្រុមដែលមានសមាជិកសុទ្ធតែជាមនុស្សចិត្តមិនត្រង់ មនុស្សគ្មានសេចក្ដីសុចរិត? មុននឹងចុះសេចក្ដីសន្យា ត្រូវគិតដូចម្ដេចជាមុន? ក្នុងប្រភេទណាដែលគួរលើកចោលនូវសេចក្ដីសន្យា? ចៅហ្វាយនាយនឹងបាវព្រាវត្រូវគោរពខសន្យារវាងគ្នានឹងគ្នាដូចម្ដេចខ្លះ?

## មេសូត្រ

## សត្វស្រមោចនឹងរៃ

នៅវេលាចុងសរទរដូវ ចូលមកក្នុងរដូវរងា ស្រមោចទាំងឡាយដែលតែងខំប្រឹងពុំឈប់ឈរ ស្វែងរកអាហារលើគុម្ពស្មៅក្រៀមទាំងឡាយ យកមកទុកដាក់ក្នុងជង្រុករបស់ខ្លួន បានឃើញសត្វរៃមានមុខស្រពោន ខ្លួនស្គមកំព្រឹងរកកល់ទីស្លាប់ ដោយគិតតែច្រៀងរាល់ថ្ងៃឥតឈប់ឈរ ក៏មានចិត្តអាណិត ពោលទៅកាន់សត្វរៃថា: ឯងចូរទៅយកគ្រាប់ផលានុផលឯជង្រុកអញ ដើម្បីបន្ត

ជីវិតចុះ ដ្បិតថាខ្លួនឯងគ្មានបានសន្សំអាហារបន្តិចបន្តួចសោះ; ឥឡូវអញមានកំណាប់ទ្រព្យដែលនៅក្នុងជង្រុក ដោយអញបានសន្សំពីព្រាំងមិញ; ចូរឯងកុំភ័យពីការអត់ឃ្លាន ចូរចេះតែច្រៀងទៅទៀត, ឱទុគ្គតសម្លាញ់... ។

ស្រមោចដែលជាប់ក្នុងមេត្តាចិត្ត លុះត្រឡប់ចូលមកលំនៅខ្លួន ក៏ស្រាប់តែឃើញសម្បត្តិដែលទុកដាក់ក្នុងជង្រុករបស់ខ្លួន បាត់ពីឃ្លាំងអស់ ដោយកណ្ដុរជាសត្វចង្រៃ មកលួចពាំយកទៅជាអាហារវា, ឃើញមាននៅសល់តែបីគ្រាប់ក្នុងបាតជង្រុក, ប៉ុន្តែឥតមានទឹងសម្បកអ្វីទេ ទឹកមុខនៅស្រស់ញញឹម តាំងចិត្តជាប់ទឹងឲ្យទាន ស៊ូអត់ស្លាប់ខ្លួនឯង កុំឲ្យតែបង់សំដីដែលខ្លួននិយាយ ក៏ឲ្យទៅសត្វរៃអស់រលីង ។

## ពន្យល់ពាក្យ

សរទរដូវ ន. រដូវអ័ត្ថ រដូវរំហើយ; កាលកំណត់ដែលចែកជាភាគក្នុងឆ្នាំនីមួយ ៗ តាមសម័យដែលអាកាសប្រែប្រួល;

តាមសុរិយគតិ ក្នុងមួយឆ្នាំៗ និយម ប្រើរដូវ ៤ គឺ: ១-និទាឃរដូវ (រដូវក្តៅ) បារាំងហៅ (ប្រ័ងតង់) មានបីខែ, រាប់ពីថ្ងៃទី ២១ មីនៈ (មារ្ស) ដល់ថ្ងៃទី ២១ មិថុនៈ (យូអាំង) មាន ៩៣ ថ្ងៃ ។ ២- វស្សានរដូវ (រដូវភ្លៀង), បារាំងហៅ (អេតេ) មានបីខែ, រាប់តាំងពីថ្ងៃ ២២ មិថុនៈ (យូអាំង) ដល់ថ្ងៃ ២២ កញ្ញា (សេបតំប្រ៍) មាន ៩៣ ថ្ងៃ ។ ៣-សារទរដូវ (រដូវចុះអ័ព្ទ, រដូវមានខ្យល់ភ្លៀងទឹកសសើម, រដូវលំហើយ); បារាំងហៅ (អូតូម) មាន ៣ ខែ, រាប់តាំងពីថ្ងៃ ២៣ កញ្ញា (សេបតំប្រ៍) ដល់ថ្ងៃ ២១ ធ្នូ, (ដេសំ-ប្រ៍) មាន ៩០ ថ្ងៃ ។ ៤- សិសិររដូវ (រដូវរងាខ្លាំង), បារាំងហៅ (អ៊ីវែរ) មានបីខែ, រាប់តាំងពីថ្ងៃ ២២ ធ្នូ (ដេសំប្រ៍) ដល់ថ្ងៃ ២០ មីនៈ (មារ្ស) មាន ៨៩ ថ្ងៃ ឬ ជួនកាល ៩០ ថ្ងៃ ។ រួមទាំងបួនរដូវត្រូវជា ១២ ខែ មាន ៣៦៥ ឬជួនកាលមាន ៣៦៦ ថ្ងៃ ជាមួយឆ្នាំនៃសុរិយគតិ (មិនមានវិធីលើកខែទេ) ។ តាមចន្ទគតិក្នុង ១ ឆ្នាំៗ និយមប្រើរដូវ ៣ គឺ ១ ហេមន្តរដូវ, ២ គិម្ហរដូវ, ៣ វស្សានរដូវ ។ ក្នុងរដូវនីមួយៗមាន ៤ ខែ.។ ។

កំព្រឹង គុ. ដែលស្គមណាស់ស្ទើរតែដាច់ឆ្អឹង : ស្គមកំព្រឹង, កង់កំព្រឹង ។

ទុគ្គតសម្លាញ់ ន. សម្លាញ់ខ្សត់ទ្រព្យ : ធ្វើម្ដេចខ្ញុំជាទុគ្គតបុរស ។

* * * *

មេរៀនទី ៤៦ ចិត្តសប្បុរស

**Devoirs de charité**

ចិត្តល្អ

**La bonté.**

១- សប្បុរស គឺបុរសអ្នកស្ងប់ មនុស្សចិត្តល្អ បានដល់ប្រុសក្ដី ស្រីក្ដីអ្នកមិនធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត, អ្នកប្រព្រឹត្តល្អ, អ្នកត្រឹមត្រូវ ។ មនុស្សពួកនេះលោកហៅថាពួកសប្បុរស មានចិត្តសប្បុរស មានសំដីសប្បុរសគ្នា ។

អធិប្បាយថា : មនុស្សសប្បុរស គឺជាមនុស្សចិត្តល្អ ប្រកបដោយមេត្តាករុណា មិនមានរើសមុខ ស្រឡាញ់រាប់រកដូចជាកូនចៅលើសពីសាច់ឈាមខ្លួន ឬដូចជាបងប្អូនបង្កើត ជួយកិច្ចធុរៈដោះ

ទុក្ខគ្នាទៅវិញទៅមកគ្រប់អន្លើ ។ មនុស្សគ្មានមេត្តាករុណា គ្មានចិត្តល្អនឹងគ្នា, នោះទុកដូចជាពុំមែនជាមនុស្សជាតិ ។ ហេតុនោះមានតែចិត្តល្អនេះឯងហើយ ដែលអាចនឹងទាក់ទាញមនុស្សឲ្យទុកចិត្តស្រឡាញ់គ្នាដោយស្មោះត្រង់ទៅបាន ។

២- មនុស្សចិត្តល្អ គឺមនុស្សមានសំដីផ្អែមល្ហែម ធ្វើឲ្យគេឯងសប្បាយ ដោយសំដីនឹងដោយកិច្ចការណាមួយ ហើយបកសេចក្ដីសុខឲ្យគេឯង ធ្វើឲ្យគេស្គាល់ខ្លួនបានថាជាមនុស្សមានចិត្តស្មោះត្រង់ ជួយឈឺឆ្អាលគេគ្រប់វេលាណាមួយ, ម៉្លោះហើយមនុស្សទាំង-ឡាយតែងតែចូលចិត្តស្រឡាញ់រាប់រក ។

៣- ឯមនុស្សកំណាញ់ គឺជាមនុស្សផ្ទុយនឹងមនុស្សចិត្តល្អ ។ ដើម្បីឲ្យបានជាមនុស្សសប្បុរសនឹងមនុស្សចិត្តល្អ ត្រូវហាត់បំភ្លេចខ្លួនឯង ។

អធិប្បាយថា: មនុស្សសប្បុរសក្ដី មនុស្សចិត្តល្អក្ដី គឺមនុស្សមិនចេះរករឿងគុំគួន រករឿងជេរវាយសម្លាប់អ្នកណា គ្មានទិន្នាគេចង់ឲ្យតែគេមានបានដូចខ្លួនដែរ ។ មនុស្សកំណាញ់តែងតែមាន

សេចក្ដីប្រណែន ហើយបើនៅតែមានសេចក្ដីសន្ទិះសង្ស័យ ពុំសូវសប្បាយ ឬបើនៅតែជួបប្រទះនឹងគេធ្វើទុក្ខទោសផង ។

៤– សាលារៀន ជាទីទំនុកបម្រុងឲ្យកើតគុណសម្បត្តិខាងចិត្តប្បៀស ចិត្តល្អ មូលមិត្រសាមគ្គីគ្នា ។

អធិប្បាយថា: នៅទីសាលា កុមារទាំងឡាយប្រែជាអ្នកស្រឡាញ់គ្នា ដូចបងប្អូនបង្កើត ។ បើក្នុងពួកណាតូចជាងខ្លួនអ្នកៗ ត្រូវការពារ, លួងលោមក្នុងគ្រាមានទុក្ខទាំងពួងដែលកើតមានឡើង ជួយបំពេញកិច្ចការគ្នាទៅវិញទៅមក, កុំធ្វើទុក្ខបុកម្នេញគ្នីគ្នា, កុំរិះគន់និយាយដើមគ្នាឡើយ ។

## ការអាន

## លក្ខណចិត្តល្អ

បុរសទាំងឡាយត្រូវមានចិត្តឲ្យល្អ គឺប្រព្រឹត្តគិតរកធ្វើតែអំពើដ៏ប្រសើរគាប់ចិត្តគ្រប់អ្នកទាំងពួង ។

១– ឲ្យករុណាមេត្តាសង្គ្រោះសន្ដោសអ្នកកំសត់ទុគ៌ត, បើ

ឃើញបើប្រទះ អ្នកកំសត់ទុគ៌តនៅទីណា, កុំឲ្យត្មះតិះដៀលពោលពាក្យត្រគោះឲ្យអាក់អន់ចិត្ត, បើជួនជាដើរទៅប្រទះនឹងមនុស្សពោលព្រហើនគោងកាចដើរមកប៉ះទង្គិច ឬនិយាយពាក្យគម្រោះគម្រើយមកឲ្យ, កុំឲ្យប្រកាន់ចិត្តខឹងតបគំនុំគុំគួនឡើយ ព្រោះវាជាមនុស្សពាល ។

២ — បើអ្នកកំសត់ទុគ៌តមករកសូមទានភោជនអាហារ មិនត្រូវកន្ទ្រិះស្តីរឡើយ បើមានល្មមចែករំលែកបាន ក៏ឲ្យចែករំលែកឲ្យទានទៅ; បើគ្មានគួរតែមានវាចាល្អទៅកាន់អ្នកកំសត់ទុគ៌តនោះវិញ ។

បើមនុស្សណាមួយគិតធ្វើអំពើអាក្រក់ទំនឹងយើងៗដឹងខ្លួនជាមុន គួរយើងគេចចៀសវាងការពាររក្សាខ្លួនយើង កុំឲ្យអន្តរាយ, តែកុំឲ្យប៉ងប្រាថ្នាព្យាបាទឲ្យថ្ងោះការបង់ដល់រូបកាយគេវិញ នោះទើបហៅថាចិត្តល្អប្រកបដោយធម៌ ។

បើគ្នាឯងមានការឈឺថ្កាត់ តោងជួយរកថ្នាំថែទាំរក្សាគ្នា; បើវារៀនពូកែចេះដឹងច្រើន ត្រូវជួយអរសាទរ, ដ្បិតជាកេរ្តិ៍ឈ្មោះរបស់សាលាយើង ។

ម្យ៉ាងទៀតត្រូវឲ្យមានវាចាល្អ ចិត្តល្អ បើឃើញចាស់ទូលរែករបស់ធ្ងន់ៗ ត្រូវស្ទុះទៅជួយ មិនត្រូវធ្វើព្រងើយកន្តើយឡើយ ។ ត្រូវចេះដឹងគុណអ្នកដែលមានគុណលើយើង, កុំគប្បីបំភ្លេចគុណគេ; នេះហើយហៅថាមនុស្សសប្បុរសចិត្តល្អ មានគុណសម្បត្តិល្អព្រម ។

*ចោទសួរ* ពាក្យថាសប្បុរសបានសេចក្តីយ៉ាងណា? ដូចម្តេចហៅថាមនុស្សចិត្តល្អ? មនុស្សកំណាញ់ផ្ទុយនឹងមនុស្សចិត្តល្អដូចម្តេច? នៅសាលារៀនកុមារទាំង-ឡាយត្រូវធ្វើចិត្តនឹងគ្នាដូចម្តេចខ្លះ? ចំពោះមនុស្សកំសត់ទុគ៌តអ្នកត្រូវធ្វើដូចម្តេច?

## ការអាន

## ត្រូវជួយគ្នាទៅវិញទៅមក

អ្នកឲ្យសុខគេៗនឹងឲ្យសុខវិញ, អ្នកឲ្យទុក្ខគេៗនឹងសងទុក្ខវិញ ។ មានសត្វលលកមួយ ហើរទៅបានឃើញពួកស្រមោចធ្លាក់ទៅក្នុងទឹក ហែលតោងតែគ្នាឯង មានចិត្តករុណាពួកស្រមោចនោះ ទើបទៅពាំយកមែកឈើងាប់ ១ មកដាក់ធ្វើជាស្ពានឲ្យស្រមោចអស់នោះតោងតះឡើងមកលើគោកបាន ។

ស្រមោចទាំងឡាយបានរួចពីក្ដីស្លាប់ ដោយអំណាចឈើស្ពានដែលលលកដាក់ឲ្យខ្លួនតោងវារឡើងនោះឯង ។

ថ្ងៃមួយលលកហើរទៅទំលើមែកជ្រៃ ។ ដួនជាព្រានប្រមាញ់ម្នាក់ ដើរទៅឃើញលលកទំលើមែកជ្រៃ ក៏ប្រាថ្នានឹងបាញ់ ។ ឯស្រមោចទាំងឡាយ ដឹងថាព្រានប្រមាញ់ប៉ងនឹងបាញ់លលកដូច្នោះ ក៏នឹកដល់គុណលលកដែលបានធ្វើគុណលើខ្លួន ទើបនាំគ្នាវារឡើងខាំជើងនាយព្រាន ដើម្បីឲ្យនាយព្រាននោះភ្ញាក់កន្ទ្រាក់ ទន្ទ្រំជើងឲ្យព្រួសឡើង ឲ្យលលកបានដឹងខ្លួនហើយហើរទៅ ។ កាលដែលនាយព្រានកំពុងតែស្រងើរក្នុងគិតបាញ់, ស្រមោចក៏ឡើងរោមខាំៗ ព្រានក៏ធាក់ជើងព្រួសរឹបៗ ។ ឯលលកបានព្រួសសព្ទដូច្នោះហើយ ក៏បែរមើលទៅឃើញមនុស្សប៉ងនឹងយាយខ្លួន ទើបស្ទុះហើរចាកមែកជ្រៃនោះ ទៅកាន់ទីដទៃផុតក្ដីស្លាប់ហោង ។

## មេសូត្រ

សុខអើយសុខា នរអ្នកណា អាចឲ្យសុខគេ គេនឹងបំពេញសុខវិញមិនទេ បើឲ្យទុក្ខគេ គេឲ្យទុក្ខស្នង ។ នរណាធ្វើគុណ

គុណគន់ការុណ្យ នាំសុខមកសង់ នរណាធ្វើទោស ទោសគន់អន្ទង នាំទុក្ខមកសង់ ឲ្យវេទនា ។

## ពន្យល់ពាក្យ

លលក ន. សត្វបក្សីស្លាបគោក មានសម្បុរពព្រុះ ។

គោងការ កិ. កាន់គោងធ្ងន់ ។

យាយី កិ. បៀតបៀន, រករឿងសម្លាប់ ។

ស្រងេះភ្លេក កិ. ន. ធ្វើកែកត្បូចម្ខាង ។

ដឹងខ្លួន ន. កិ. ផុតភ័ទុក, រូបខ្លួន ។

ប្រព្រឹត្ត កិ. ប្រឹងប្រែបខ្លួន ។

ព្រានប្រមាញ់ ន. អ្នកបាញ់សត្វ ។

ទន្ទ្រំ កិ. ធ្វើសួរដើឲ្យក្ត ។

អន្ទង កិ. ណែនាំ, ប្រមូល ។

ការុណ្យ ន. សេចក្ដីអាសូរ ។

* * * *

## មេរៀនទី ៤៧ យ៉ាងដូចម្ដេចដែលហៅថាក្រសួងមហាជន

ពាក្យថាក្រសួងមហាជន គឺក្រសួងដែលធ្វើការឲ្យផលដល់ជនទាំងឡាយមិនរើសមុខថាអ្នកណាជាអ្នកណា ៗ ឯក្រសួងសម្រាប់ឯកជន គឺក្រសួងដែលធ្វើការឲ្យផលប្រយោជន៍ដល់ជនមួយក្រុមឬតែម្នាក់ប៉ុណ្ណោះ ៗ ដូច្នេះឃើញថា ក្រសួងដែលរាជការកាន់កាប់ជាក្រសួងសម្រាប់មហាជន ៗ ចំណែកក្រសួងដែលសមាគមកាន់កាប់ ដូចជាក្រសួងរបស់ក្រុមហ៊ុនទឹកភ្លើង សាលាឈ្នួល ក៏ចាត់ថាជាក្រសួងមហាជន ដូចជាក្រសួងដែលរាជការកាន់កាប់ដែរ ៗ

ប៉ុន្តែបើគិតតាមអ្នកប្រើប្រយោជន៍វិញ គឺក្រសួងនេះសម្រាប់តែមនុស្សមានប្រាក់; ដូច្នេះត្រូវរាប់ហៅថាក្រសួងសម្រាប់ឯកជនវិញ ៗ បើមនុស្សភាគច្រើន អាចបានប្រយោជន៍អំពីសមាគមណាមួយ, សមាគមនោះ ពិតមែនតែមិនមែនជារបស់រាជការ ក៏នៅជាក្រសួងសាធារណៈសម្រាប់មហាជនដែរ ៗ ឧ. ដូចជាក្រសួងកាន់កាប់យានជំនិះយន្តហោះជាដើម ៗ បើយ៉ាងនេះឃើញថាមិនងាយនឹងស្គាល់ក្រសួងសម្រាប់មហាជនមួយពួកមួយក្រុមនេះទេ, ប៉ុន្តែគេអាច

សំគាល់ក្រសួងសម្រាប់មហាជនបាន ៣ យ៉ាងដូច្នេះ គឺ :

ក) ក្រសួងសម្រាប់មហាជន សំដៅយកក្រសួងណាដែលបំពេញបំណងទូទៅ ហើយយ៉ាងវិសេសរបស់អ្នកស្រុក ដូចសមាគមអ្នកដុតនំបុ័ង នៅស្រុកបារាំងជាដើម ។

ខ) ក្រសួងសម្រាប់មហាជន សំដៅយកក្រសួងរបស់ឯកជនណាដែលរាជការជួយទំនុកបំរុងជាប្រាក់កាស (subvention) ដើម្បីការពារប្រយោជន៍មហាជន ។

គ) ក្រសួងសម្រាប់មហាជន សំដៅយកក្រសួងណាដែលរាជការកាន់កាប់ ។

* * * *

## មេរៀនទី ៤៨ អ្នករួមជាតិចំពោះក្រសួងសំរាប់មហាជន ដែលរាជការកាន់កាប់

ច្រើនគ្នាណាស់ ឬសឹងតែទាំងអស់គ្នា, តែក្រសួងមិនចំពោះខ្លួនម្នាក់ៗ ច្រើនតែធ្វើដោយធ្វេសប្រហែស មិនខំឲ្យចំរើន ពីព្រោះគ្មានគេនឹងប្រណាំងៗ ម្យ៉ាងវិញទៀត ក្រសួងបែបនេះ បើទុកជាខាត

ចំណេញស្រេចនៅលើរាជការ គ្មានប៉ះពាល់ដល់អ្នកធ្វើការផង មកពីបានប្រាក់បៀរ៍រាល់រូបនរណាក៏ដូចនរណា ៗ

មួយវិញទៀត បើទុកជានរណាមានចិត្តចង់បំពេញមុខក្រសួង ក៏មិនសូវមានចិត្តចង់រកការធ្វើប៉ុន្មាន ព្រោះគេមិនសូវមើលឃើញ ហើយធម្មតាគ្រាន់តែធ្វើតាមបង្គាប់នាយៈចៅហ្វាយទៅក៏បានហើយ ៗ ដូច្នេះស្រេចតែម្នាក់ ៗ បេះគិតឃើញទេ, បើគិតឃើញថាក្រសួងនេះមានប្រយោជន៍ដល់ខ្លួន ក៏គោនតែជួយក្រសួងនោះឲ្យនៅគង់ទ្រង់បានយូរទៅ គឺកុំធ្វេសប្រហែសនឹងការងារ ហើយនឹងការបង់ពន្ធ ៗ

ម្នាក់ៗមានអំណាចអាចទទួលប្រយោជន៍អំពីក្រសួងមហាជនបាន ៗ ព្រោះក្រសួងជាច្រើន ដែលរវល់តែនឹងបំពេញបំណងមហាជនទាំងអស់ នឹងជួយអ្នកក្រីក្រផង ដូចក្រសួងនគរបាល, ក្រសួងសិក្សាធិការ, ក្រសួងប្រជាសង្គ្រោះផ្សេង ៗ ជាដើម ៗ

យើងទាំងអស់គ្នាពិតជាមានអំណាចអាចទទួលប្រយោជន៍អំពីក្រសួងផ្សេង ៗ បានជាប្រាកដ ៗ

ក្នុងសម័យសព្វថ្ងៃនេះដែលអ្នកស្រុកមានអំណាចស្មើគ្នា មិនដូចកាលពីដើម ដែលគេគិតនាម៉ឺនដោយខ្សែកក្រស្តដោយខ្សែកនោះទេ, គឺនរណាក៏ដូចនរណា អាចសុំស៊ីបានដូចគ្នា ឲ្យតែត្រូវការ, មិនត្រូវនឹងថាមានអ្នកណាមួយដាក់ទានឲ្យយើងឡើយ ព្រោះថាយើងមានសិទ្ធិស្មើគ្នាស្រាប់ ៗ ទោះបីដូច្នោះក៏គង់នៅមានមនុស្សខ្លៀតឲ្យប្រយោជន៍មិនសមហេតុចំពោះអ្នកដែលខ្លួនរាប់អាន ដោយយោគយល់មុខទៀតពុំខាន ៗ អ្នកនេះធ្វើដោយការរំលោភទេ បើដូច្នេះត្រូវតែរកផ្លូវបំបាត់ការរំលោភនេះឲ្យអស់ ៗ

ចោទសួរ - ដូចម្តេចហៅថាក្រសួងមហាជន? ពលរដ្ឋត្រូវធ្វើដូចម្តេចចំពោះក្រសួងនេះ? ក្រសួងមហាជនមានប្រយោជន៍អ្វីខ្លះដល់មហាជន? មហាជនអាចនឹងទទួលប្រយោជន៍អ្វីខ្លះពីក្រសួងនេះ?

* * * *

## មេរៀនទី ៤៩ ការបេះគួរសម

**la politesse - la courtoisie - labonne grâce.**




ការបេះគួរសម គឺបេះធ្វើកិរិយាដាក់ខ្លួនរាប់រកអ្នកដទៃ មិនត្រឹមតែមិនឲ្យទាស់ចិត្តគេប៉ុណ្ណោះឡើយ រហូតដល់ទៅបេះធ្វើឲ្យគេសប្បាយចិត្តផងទៀតដែរ ។ ការប្រព្រឹត្តធ្វើឲ្យអ្នកដទៃពេញចិត្តនឹង

ខ្លួនយើង ក្នុងកិច្ចប្រាស្រ័យទាក់ទងនៅក្នុងសង្គម ដើម្បីចៀសវាងនូវសេចក្តីទាក់ទងឈ្លោះប្រកែក ប្រៀបដូចប្រេងខ្លាញ់ ដែលគេត្រូវការដាក់គ្រឿងចក្រដើម្បីឲ្យវិលទៅបានស្រួល គ្មានលាន់សូរ ។ មនុស្សគ្មានកិរិយាគួរសម រមែងធ្វើកិច្ចការអ្វីៗពុំបានសម្រេចផល ច្រើនប្រទះឧបសគ្គ ដូចគ្រឿងចក្រដែលវិលទៅ ឥតប្រេងខ្លាញ់សម្រាប់លាប តែងពុកស៊ូរ ឬស្និតគេះគ្រៀតទៅពុំរួចដូច្នោះ ។ ដូច្នេះអ្នកចេះគួរសម ត្រូវកាន់ចិត្តល្អរកអ្នកដទៃ ស្រឡាញ់អ្នកដទៃនោះដូចបងប្អូន; នោះហាក់ជាកិច្ចមួយដែលបណ្តាលឲ្យគេមានសេចក្តីរីករាយនឹងខ្លួន ។

ច្បាប់សម្រាប់ប្រតិបត្តិក្នុងការគួរសម ក្នុងទីណាមួយ ហៅថាសុជីវភាព (Le savoir vivre) ច្បាប់នេះមានច្រើនយ៉ាង :

ការប្រព្រឹត្តតាមច្បាប់សណ្តាប់ធ្នាប់អ្នកក្រុង ដែលហៅថាបោរីភាព (Civilité) គឺប្រើពាក្យនឹងសំដីគួរសមតាមគួរតាមជំនិនឲ្យត្រង់ ឧបមាដូចជាយើងដើរប៉ះគេ ត្រូវតែសូមទោសគេ ឬក្នុងចំណោមណាមួយ យើងត្រូវតែគួរសមនឹងមនុស្សសូម្បីដែលយើង

មិនចូលចិត្តសោះក៏ដោយ ។

ការប្រព្រឹត្តិសេចក្ដីគួរសមក្នុងឋានៈនៃខ្លួនជាអ្នកធំ ត្រូវមានជានិច្ចក្នុងការត្រួតត្រាលើខ្លួន អំណត់សេចក្ដីអត់ធន់មិនខឹង ទឹងគំនិតសិក្សក្នុងការងារដើម្បីជាប្រយោជន៍ដល់អ្នកដទៃ ។

មនុស្សគួរសម ចេះផ្ចាញ់សេចក្ដីលោភ ជំនះសេចក្ដីខ្ជិលទឹងសេចក្ដីប្រច្ឆា ហើយមិនគិតតែប្រយោជន៍ផ្ទាល់ខ្លួនឡើយ ។ គេបើកមួកគំនាប់ ឬក្រោកឈរច្រើនដងច្រើនគ្រាឥតមានធុញទ្រាន់ ឬឲ្យកន្លែងដែលគេអង្គុយទៅដល់ស្រី ហើយស៊ូឈរមិនខ្លាចលំបាក ។

កិច្ចទាំងនេះគេបំពេញបាន លុះត្រាតែខំប្រឹង លុះត្រាតែចេះជំនះ លុះត្រាតែខំប្រឹងកាត់សេចក្ដីល្ងង់ចេញ ដែលជាគ្រឿងប្រាថ្នាតែម្ហូបបំណើល្អ ។

ការគួរសមជាមធ្យោបាយបង្ហាញថា យើងមានសេចក្ដីគោរពដល់កិត្តិយសជនដទៃ ។

មនុស្សគួរសម មិនធ្វើ មិននិយាយឲ្យជំទាស់អាក់អន់ដល់អ្នកជិតខាង, ចេះប្រព្រឹត្តតាមសេចក្ដីស្លូតត្រង់ ចេះរាក់ទាក់ គឺចេះនិយម

អនុលោមតាមសុជីវធម៌ ដែលគេត្រូវប្រតិបត្តិតាមថ្នាក់សក្តិយសនៃបណ្តាជន គឺត្រូវបេះបន្ទន់បន្ទាបលុតក្រាបទន់ភ្លន់សមតាមរបៀបថ្នាក់មនុស្ស ជាកិរិយាចាំបាច់ដែលគេប្រើក្នុងចំណោមនីមួយៗ ៗ មនុស្សគួរសម តែងជាក់បុកពាខាងក្រៅឲ្យសមតាមចិត្តគំនិតដ៏ស្មោះត្រង់ ។

សុជីវធម៌របស់ខ្មែរយើង មានជាដំណគតពីឪពុកម្តាយយើងដោយការបង្ហាត់បង្រៀនតាមច្បាប់ក្រមជាដើម នឹងការប្រព្រឹត្តិធ្វើតាមគ្នា ជាលំដាប់ដកបរៀងកបមក, ប៉ុន្តែទោះបើសណ្តាប់ធ្នាប់ខាងសេចក្តីគួរសមនោះ ពីដើមល្អយ៉ាងណាក្តី ក៏តែងប្រែក្លាយទៅជាផ្សេងគ្នាតាមទេសៈកាលៈ ហើយតែងប្រែក្លាយព្រោះការច្រឡំវប្បធម៌របស់ប្រទេសផង ព្រោះមិនសូវយកចិត្តទុកដាក់ក្នុងទំនៀមទម្លារបស់ប្រទេសផង ។ ឯសុជីវធម៌របស់បារាំងក៏មានដូច្នោះដែរ ប៉ុន្តែជ្រៅជ្រះណាស់ ថែមទាំងឥតប្រែក្លាយផង ព្រោះគេបានចងជាច្បាប់ទុកក្នុងសៀវភៅបង្រៀនជាប់តមក ។

ប៉ុន្តែត្រូវដឹងថា បេះច្បាប់ហើយមិនបេះប្រើកឥតអំពើ ៗ ដោយហេតុនេះបានជាកូនខ្មែរយើងពីដើម ស្រីៗគេតែងតែយកទៅផ្ញើនឹង

ត្រសារស្តេច, ឬសាឲ្យទៅនៅវត្ត ឬផ្ញើទំងនាម៉ឺនធំៗ ដើម្បីឲ្យគេប្រើច្បាប់នេះៗនៅស្រុកបារាំងគេមានសាលាសម្រាប់បង្រៀនសិស្សឲ្យចេះរៀបចុកពា និយាយទំងភ្ញៀវ ឬទទួលភ្ញៀវឲ្យសមរម្យ ៗ

សំនួរ– ដូចម្តេចហៅថាការគួរសម? ដូចម្តេចហៅថាសុជីវភាព? មនុស្សចេះគួរសមត្រូវដឹងអ្វីខ្លះ? ចូរអធិប្បាយពីការគួរសមនៅវេលាដែលជួបប្រទះនឹងអ្នកធំ ប្រទះនឹងមិត្តភក្តិអ្នក?

## កំណត់សំគាល់

១– ក្នុងការប្រតិបត្តិតាមច្បាប់សុជីវធម៌ មិនត្រូវធ្វើឆាក់តែគួរ នាំឲ្យគេសើចចំអន់ទៅវិញនោះឡើយ ៗ

២– ទោះច្បាប់សុជីវធម៌ពិបាកយ៉ាងណាក៏ដោយ យើងត្រូវប្រព្រឹត្តតាមជាដរាប ពីព្រោះមនុស្សយើងម្នាក់ៗ មិនមែននៅម្នាក់ឯងទេ គឺតែងស្ថិតនៅក្នុងសង្គម ៗ

## ការប្រព្រឹត្តដូចម្តេចដែលហៅថាការគួរសម

ការគួរសមជាគុណយ៉ាងមួយរបស់អំណាចចិត្តទំងនួៈ ចេះលាក់ការស្មាត់កំបាំង ដែលអ្នកដទៃមានទុកក្នុងចិត្តលើៗ ក៏ចូលប្រព្រឹត្ត

បែបនេះជាមធ្យោបាយចង្អុលបង្ហាញថា យើងមានសេចក្ដីគោរពចំពោះជនដទៃ ហើយជាផ្លូវបណ្ដាលឲ្យជនជិតខាងចូលចិត្តប្រាស្រ័យចុះឡើង ។

តើអ្នកមានសេចក្ដីរីករាយដែរឬទេ ,បើក្នុងទីក្រសួងធ្វើការណាមួយ មានអ្នករាជការសាកសួរអ្នកដោយរាក់ទាក់ ហើយជួយបំពេញកិច្ចអ្នកដោយរួសរាន់ ?

តើអ្នកស្រាកស្រួលបន្តិចទេ ក្នុងសេចក្ដីសុខស្រួលរបស់អ្នក នៅពេលដែលអ្នកផងទាំងពួងជួយនិយាយលួងលោម ជួយសំរាលទុក្ខទោស ?

ការគួរសមជាតួយ៉ាងមួយនៃសេចក្ដីសប្បុរស ។ ពិតមែនតែសេចក្ដីគួរសម ខុសពីសេចក្ដីសប្បុរស, ប៉ុន្តែគេទុកសេចក្ដីគួរសមដូចជាសេចក្ដីសប្បុរសមួយដែរ ពីព្រោះសេចក្ដីគួរសមបែកចេញពីចិត្តមក ។

ពាក្យជំរាបសួរបានសេចក្ដីថា : ខ្ញុំមានសេចក្ដីរីករាយដោយបានជួបនឹងអ្នក ខ្ញុំជូនពរអ្នកឲ្យបានសេចក្ដីសុខចំរើន ក្នុងថ្ងៃនេះ ។

អរគុណ (merci) បានសេចក្ដីថា: ខ្ញុំអរគុណដោយហេតុថា អ្នកបានជួយបំពេញកិច្ចការនេះ ។

អត់ទោស បានសេចក្ដីថា: ខ្ញុំអង្វរអ្នក ឲ្យអ្នកមេត្តាអត់ទោស ឲ្យ ពីព្រោះខ្ញុំបានប្រព្រឹត្តដោយប្រឡំ ធ្វើឲ្យអ្នកអាក់ខានក្នុងពេល នេះ ។

•

### ទឹកមុខស្រស់ស្រួល, ការទៀងទាត់

ក) ទឹកមុខស្រស់ស្រួលជាគ្រឿងមួយដែរ ក្នុងការគួរសម ដោយសេចក្ដីក្លាហាន ។ ក្នុងពេលមានភ្ញៀវ មនុស្សគួរសមតែងធ្វើ ទឹកមុខស្រស់ ហើយទទួលគេដោយរាក់ទាក់ ហាក់ដូចជារីករាយ ដោយបានឃើញភ្ញៀវនោះមក ទោះបីមានសេចក្ដីខ្សឹកខ្សួលយ៉ាង ណាក៏ដោយ ។ នេះបង្ហាញថា ជនបែបនោះមានសេចក្ដីគួរសម មានសេចក្ដីក្លាហាន ។ បើប្រសិនជាមានមនុស្សធ្វើទឹកមុខអាក្រក់ មួហ្មងទឹងរឿងផ្សេង ៗ ហើយប្រើពាក្យគំរោះក្នុងទីប្រជុំណាមួយ ឬក្នុងគ្រួសារ តើអ្នកមានទឹកមុខបែបណា ? បណ្ដាជនក្នុងចំណោម ធ្វើបុណ្យរីករាយដែរឬ ? ត្រង់នេះបង្ហាញឲ្យឃើញថា ធ្វើទឹកមុខ

ស្រស់ល្អក្នុងបទការគួរសមប្រាកដ ៗ

១) សេចក្ដីទៀងទាត់ក៏ជាត្បូងយ៉ាងមួយដែរក្នុងការគួរសមភាព ព្រោះជាផ្លូវបង្ហាញឲ្យឃើញថា យើងមានចិត្តនឹកដល់គេ ខ្លាចគេទន្ទឹងចាំមើលយើង ៗ តើអ្នកយល់ឃើញយ៉ាងដូចម្ដេចមនុស្សដែលខ្ចីសៀវភៅអ្នក លុះដល់ពេលសន្យាហើយមិនឃើញយកទៅសងអ្នកវិញ ? មនុស្សដែលទៅមិនទាន់ពេលម៉ោងសន្យា ?

* * * *

## មេរៀនទី ៩០ គំនិតយល់ខុសឬត្រូវ

## Esprit critique

ត្រូវតែស្ដាប់វិទ្យុមើលកាសែតដោយមានគំនិតរកខុសត្រូវ ៗ ឲ្យមានគំនិតនេះ កុំឲ្យចេះតែឃើញអាក្រក់ឬឃើញកំហុសរបស់គេនៅតែគ្រប់កន្លែង ត្រង់ខ្លួនឯងមិនខុសអ្វីនោះទេ ៗ តោងឲ្យចេះត្រួតមើល តើពាក្យដែលឃើញឬស្ដាប់ឮនោះមានតម្លៃដែរឬទេ ? គួរជឿតាមឬមិនគួរ ?

ដូច្នេះអ្នកដែលមានគំនិតរកខុសត្រូវ គឺជាអ្នកដែលចេះត្រួត

មើលថាតើពាក្យដែលឃើញឬឮជាពាក្យខុសឬត្រូវ ល្អឬអាក្រក់ ។

ក) ការពិចារណាដំណឹងផ្សេងៗ (critique des information)

មន្ទីរឃោសនាការ ជាមន្ទីរផ្សាយដំណឹងដល់បណ្ដាស្រុកផង ដល់បក្សពួកដែលកាន់អំណាចផង ។ មន្ទីរនេះនៅពេលខ្លះមិនអាចយកដំណឹងពិតមកផ្សាយឡើយ ច្រើនតែដើរតាមផ្លូវកណ្ដាល ដោយខ្លាចមានចលាចល ដោយបំណងចង់ទុកសេចក្ដីសុខ ។ ត្រង់នេះយើងមិនជាយល់ទាស់ទេ តែយើងត្រូវប្រយ័ត្នខាងកាសែតកាន់បក្សពួកមួយៗវិញ ។

នៅក្នុងកាសែតបក្សពួកនយោបាយផ្សេងៗច្រើនកាន់ជើងបក្សពួកខ្លួន ។ រិះគន់ជេរប្រមាថរដ្ឋមន្ត្រីដែលមិនមែនជាបក្សពួករបស់ខ្លួន ទោះអ្នកធ្វើការល្អយ៉ាងណាក៏ដោយ ឬក៏សរសើរអ្នកដែលជាបក្សពួករបស់ខ្លួន បើទុកជារដ្ឋមន្ត្រីនោះធ្វើការមិនបានផលក៏ដោយ ។ ដូច្នេះយើងឃើញថាកាសែតរបស់បក្សពួក ច្រើនកាន់ជើងខ្លួនៗ ។ ដើម្បីយកការពិត ត្រូវតែមើលកាសែតទាំងឡាយរបស់គូសត្រូវទាំងសងខាង ឬកាសែតដែលគ្មានបក្សពួកនោះ ។ និយមធ្វើដូច្នេះនឹង

ឃើញការពិតមិនខាន, ប៉ុន្តែត្រូវប្រយ័ត្នរហូតដល់ទៅកាសែតដែលគ្មានបក្ខពួកឬកាសែតកជការទៀតផង, ពីព្រោះអ្នកតែងកាសែតអាចមានបក្ខពួក អាចមានប្រាថ្នាបោះផ្សាយដំណឹងមិនសូវពិត មិនមានប្រយោជន៍ប៉ុន្មាន ដែលខ្លួនចង់ផ្សាយទៅត្រង់កន្លែងដែលមើលទៅមានប្រយោជន៍ ។

១) ការពិចារណាពាក្យគេថា **(critique des on dits)** ត្រង់នេះរឹតតែប្រយ័ត្នទៅទៀត ពីព្រោះមាត់មនុស្សមិនទៀងទេ ។ អ្នកដែលបានឃើញការដោយភ្នែកឯងហើយ ក៏មិនអាចបានដឹងសព្វគ្រប់ពិតប្រាកដដែរ ពីព្រោះមនុស្សយើង បើតាមពិនិត្យ នៅពេលដែលឃើញ ច្រើនតែឃើញមិនសព្វគ្រប់, ដល់ក្រោយមក ក៏ចេះតែបញ្ចេញបញ្ចូលតាមគំនិតតាមអធ្យាស្រ័យខ្លួន ដើម្បីនឹងឲ្យដំណឹងនោះមានចំរង់សេចក្ដីឡើង ។ លុះយូរទៅទៀត ដំណឹងនោះកាន់តែក្លាយខុសពីដំណឹងដើម គ្រាន់តែពីមាត់ម្នាក់ទៅមាត់ម្នាក់ក៏ឃើញខុសទៅហើយ (ភ្នែក ១ ជាភ្នែក ១០) ។ ដូច្នេះមុននឹងយកចិត្តយកគំនិតជឿធ្វើតាម, ត្រូវពិចារណារកខុសរកត្រូវ ជ្រើស

រើសស្រង់យកតែការពិត, ការមិនពិតការមិនទំនង ត្រូវចៀស ចេញឲ្យឆ្ងាយ ។

សួរចោទ – ដូចម្ដេចបានជាត្រូវប្រើគំនិតរកខុសឬត្រូវ? គួរឧស្សាហ៍ចូលទៅស្ដាប់ដំណឹងផ្សេងៗនៅទីណាខ្លះ? គួរមើលកាសែតណាខ្លះ?

•

# ការបញ្ជាក់ឡើងវិញ

## គឺការដាក់ឲ្យធ្វើ

១– អ្នកយល់ដូចម្ដេច មនុស្សដែលត្រូវនិរទេសឲ្យទៅនៅឯកោ ដាច់ម្នាក់ឯង អាចនឹងត្រៀមរកគ្រឿងផ្គត់ផ្គង់ចិញ្ចឹមជីវិតបានឬទេ ?

២– ចូរអធិប្បាយភាសិតថា "គ្មាននរណាមួយនឹងអួតខ្លួនថា មិនបាច់ទៅពឹងនរណាក៏បាន" ?

៣– ចូរពន្យល់ជាឧទាហរណ៍ពាក្យថា "ការប្រព្រឹត្តដោយយុត្តិធម៌ហើយនឹងចិត្តល្អ" ប្លែកគ្នាយ៉ាងណា ?

៤– ដូចម្ដេចដែលហៅថា : តស៊ូក្នុងរកផ្លូវច្បាប់ ?

៥– ចូរពន្យល់ពីការតស៊ូតម្នាក់នឹងម្នាក់ដែលជាបំណោះព្រៃ គ្មានបានប្រយោជន៍អ្វី ។

៦- អ្នកយល់ដូចម្ដេច ការចាប់មនុស្សយកទៅដាក់គុកដោយឥតហេតុ ?

៧- អ្នកយល់ដូចម្ដេច ការប្រព្រឹត្តជំនួញលក់ដូរមនុស្ស តើធ្វើជំនួញមនុស្សដូចកាលសម័យជាន់ដើម ?

៨- ចូរអធិប្បាយអំពីការសន្ដោសនិងការលៃលកក្នុងភោជនាហារ ។

៩- ចូរពន្យល់ថាការនិន្ទានិងធ្លាក់ទៅក្នុងសេចក្ដីឈ្នានីសគ្នាទោសឬទេ ?

១០- ចូរលើករឿងមួយជាឧទាហរណ៍ ពីការគ្នាទោសបណ្ដាលឲ្យខូចដល់វង្សត្រកូលមួយទាំងមូល ។

១១- ចូរអធិប្បាយពីការសុចរិតក្នុងភាសិតមួយថា :

"ទ្រព្យដែលបានមក ដោយមិនសុចរិត មិនជាទ្រព្យឋិតថេរទេ" ។

១២- អ្នកបានសន្យានឹងគូកនអ្នកម្នាក់ថានឹងជួយធ្វើកិច្ចការអ្វីមួយ ។ សំឡាញ់អ្នកម្នាក់ទៀតបានបបួលអ្នកទៅលេងសប្បាយ ។

អ្នកក៏បានទទួលការសរសើរ ។ ចំណែកកូនអ្នកដែលទំពឹងលើអ្នក ថាខ្លួននឹងទៅជួយធ្វើការងារក៏តែងទន្ទឹងមើលផ្លូវអ្នក ។ បើដូច្នេះតើអ្នកយល់ឃើញថាកិរិយារបស់អ្នកដូចម្ដេច ?

•

១៣ - ឧបាយណាខ្លះដែលនឹងធ្វើខ្លួនឲ្យគេស្រឡាញ់រាប់អាន?

១៤-មនុស្សកំណាញ់ អ្នកសំគាល់អាការដូចម្ដេចទើបស្គាល់ ថាជាមនុស្សកំណាញ់ ?

១៥-មនុស្សទ័លក្រទៅតែរះធ្វើទានតោកើត, ចូរអធិប្បាយ ។

១៦- កូនអ្នកម្នាក់ខឹងនឹងគេជេរ ចូរអ្នកពន្យល់កុំឲ្យប្រកាន់ ខឹង ត្រូវអត់ចិត្តល្អជាង ។

១៧- ចូរអធិប្បាយក្នុងរឿងរ៉ាវណាមួយ ដែលអ្នកបានចេះចាំ ក្នុងសៀវភៅច្បាប់ណាមួយពីការស៊ូប្ដូរដោយសេចក្ដីស្រឡាញ់ស្មោះស្ម័គ្រ ។

១៨- កូនសិស្សចេះគួរសមតើប្រព្រឹត្តអាការដូចម្ដេចខ្លះវេលា នៅផ្ទះក្ដី វេលានៅសាលារៀនក្ដី វេលានៅទីផ្សារក្ដី ?

ណែនាំ- សេចក្ដីពន្យល់នឹងសេចក្ដីអធិប្បាយរបស់ភាសិត

ទឹងចិន្តាខ្ញុំ: គួរគ្រូយកមកធ្វើជាមេតែងសេចក្ដីជាក់ឲ្យកូនសិស្សធ្វើ

ក៏ជាការស្រួល ។

ជំពូក ៧

## Chapitre VII

# ករណីយកិច្ចចំពោះប្រទេសជាតិមាតុភូមិ

## Devoirs envers la patrie

### មេរៀនទី៥១ ប្រទេស ស្នេហាជាតិ ទង់ជាតិ

### La patrie, Le patriotisme, Le drapeau

១ – ពាក្យថាប្រទេសជាតិសំដៅយកទឹកដីឬស្រុករបស់ឪពុកយើង ឬថាស្រុកដែលជីដូនជីតាយើងតែងនៅទីនេះស្លាប់ គឺស្រុកកំណើតរបស់យើង ជាទីសម្រាប់ស្លាប់សម្រាប់កប់សាកសពនៃខ្លួនយើងក្នុងថ្ងៃណាមួយ ។

អធិប្បាយថា: ស្រុកដែលបណ្ដាជននិយាយភាសាយើង មានគំនិតនឹងសេចក្ដីយល់ដូចយើង ជាអ្នកក្លាហានអង់អាច មានកេរ្ដិ៍ឈ្មោះថ្លៃថ្នូរដូចយើង ទទួលរងសេចក្ដីសុខ-ទុក្ខដូចគ្នា នៅក្រោមទង់ច្បាប់ដូចគ្នា ហើយមានគំនិតមិនចង់ឲ្យប្រទេសណាមួយមកគ្របសង្កត់បាន, រួបរួមគឺជាស្រុកទេសដែលយើងនៅអាស្រ័យ នៅជាផ្ទះរបស់យើង ដែលជាទីស្រួលជាងទីទាំងឡាយដទៃ ។

២.— ស្នេហាជាតិ  គឺស្រឡាញ់ជាប់ចិត្តចំពោះប្រទេសជាតិមាតុភូមិ  គឺជាធម្មជាតិរបស់ចិត្តដែលនាំឲ្យយើងចូលចិត្តស្រឡាញ់អស់ទាំងមនុស្សទាំងឡាយ ដែលនៅក្នុងប្រទេសជាមួយយើង ។

អធិប្បាយថា: មែនពិត យើងត្រូវស្រឡាញ់មនុស្សទាំងអស់ព្រោះជាមនុស្សជាតិដូចគ្នា,  យើងត្រូវមានការប្រាស្រ័យទាក់ទងដោយស្មោះសររាប់រកគ្នាក្នុងឋានៈជាភាតរភាព  ទាក់ទងគ្នាដោយដោតក់សន្ទាដូចគ្នា ។

ប្រទេសជាគ្រឹះសារមួយយ៉ាងធំ ត្រូវយើងស្រឡាញ់ឲ្យណាស់បន្ទាប់ពីសេចក្ដីគោរពព្រះពុទ្ធមក យើងត្រូវស្រឡាញ់គោរពប្រទេសជាតិមាតុភូមិយើង ។

៣–គ្រឿងសំគាល់របស់ប្រទេសជាតិគឺទង់ជាតិ ដែលជាគ្រឿងបូជា ៗ គេគោរពទង់ជាតិ,គេសំពះគំនាប់ទង់ជាតិ,គេដើរតាមទង់ជាតិ,គេបូជាជីវិតគេចំពោះទង់ជាតិ ។ ទង់ជាតិជាសញ្ញាយ៉ាងច្បាស់លាស់របស់ប្រទេស បង្ហាញនូវសេចក្ដីក្លាហាននៃសេចក្ដីសុខទុក្ខ ។ ទង់ជាតិនេះគេតែងតែលើកដំកុំដំកើងនៅវេលាមានបុណ្យទានផ្សេងៗ, នៅ

មុខកងទ័ពធំទាំងឡាយ. តែកាលណាទង់ជាតិលេចមុខដល់ភ្លាម, ភ្លេងស្គរត្រែ តែងបញ្ចេញសូរស័ព្ទគំនាប់ ។

៦– យើងត្រូវស្រឡាញ់ប្រទេសយើង ត្រូវនាំគ្នាបំរើប្រទេស ជាតិមាតុភូមិដោយកម្លាំងកាយកម្លាំងបញ្ញា ដោយការងារ និង ដោយសេចក្ដីស្មោះត្រង់ពីចិត្តយើង ។

អធិប្បាយថា : យើងប្រុងប្រៀបជាស្រេចនឹងបំរើប្រទេស កាលបើប្រទេសត្រូវការយើង ដើម្បីជួយឲ្យប្រទេសកុំឲ្យអាប់ជ័យ ជោគបរាជ័យ ។ យើងត្រូវសង្វាតរៀនសូត្រ ដោយភាពជាអ្នកស្នេហាជាតិ, ឲ្យចេះច្បាប់សម្រាប់ប្រទេស ហើយឲ្យចេះគោរពដល់ប្រទេសនិងទង់ជាតិដោយគារវកិច្ចដ៏ជ្រាលជ្រៅ ដល់តួប្រាសាទនគរវត្ត ដែលធ្លាប់តែមានកេរ្តិ៍ឈ្មោះរន្ទឺឮសុសសាយ តាំងពីបុរាណកាលមក ។

## ភាសិត·បិត្ត

ពួកអ្នកទទួលទណ្ឌកម្ម ព្រោះជាតិមាតុភូមិ ទុកជាអំពើក្សេមក្សាន្ត ៗ

“បុត្របុរសសាងជាតិសាសនា ស៊ូប្តូរជីវិតយកឯករាជ្យ មានចិត្តក្លាហានយ៉ាងអង់អាច ពុះពារសត្វាបក្ដីមរណា ។ មរណាៈតែខ្លួន

ជាតិរស់ពិត រូបធាតុវិបត្តិគត់តខ្ចីមសារ សូន្យចុះឲ្យសល់តែនាមា

កិត្តិស័ព្ទក៏ថ្កូអស់កាលវែង ។ ស្លាប់ក្រោមទង់ជាតិជាអគ្គប្រុស ស្លាប់

ខុសពីនេះលោកមិនថ្លៃង ស្លាប់កណ្ដាលសង្គ្រាមជាក់ស្ដែង ស្លាប់

ព្រោះធម៌សែងទៅសួគ៌ស្ថាន ។ ទទួលទណ្ឌកម្មជាតិសាសនា

មានចិត្តហាវសនាព្រឺព្រួចប្រាណ មានស្លាបហោះហើរដល់សិវឋាន

សប្បាយក្សេមក្សាន្តឥតទុក្ខភ័យ" ។

មរណៈព្រោះមាតុភូមិទុកជាជោគជ័យដែលគួរប្រាថ្នាណាស់ ។

" ស្លាប់ព្រោះជួយជាតិ គួរខំខ្នះឃ្លាត ឲ្យជាប់និស្ស័យ កើត

ជាកូនប្រុស គួរកុំអាល័យ រូបកាយក្សិណក្ស័យ កេរ្តិ៍ឈ្មោះជាប់នៅ" ។

សេចក្ដីស្នេហាចំពោះមាតុភូមិ ប្រសើរខ្ពង់ខ្ពស់ជាងអ្វីទាំងអស់ ។

"ស្រឡាញ់ខ្លួនគាប់ មិនស្មើមានភក្ដី ស្ងួនជាតិអាត្មា សូវ

ស្លាប់ខ្លួនបង់ ឲ្យជាតិថ្លៃថ្លា ព្រមទាំងសាសនា ប្រសើរថ្កើងថ្កាន" ។

កុំប្រើផឹកទិសថក្នុងកែវច្រើន ។

បើការលំបាក ប្រមូលសួរសាក កុំឲ្យបង្អង់ ប្រមូលពួកក្រុម

ពលកាតកម្រង់ ធ្វើការតាមត្រង់ កែម្ដងបានការ ។

ចោទសួរ–អ្វីខ្លះដែលហៅថាប្រទេស? ដូចម្ដេចដែលហៅស្នេហាជាតិ? អ្វីជាគ្រឿងសំគាល់ប្រទេស? កុមារត្រូវមានមនោសញ្ចេតនាដូចម្ដេចចំពោះប្រទេស? ចូរទាញភាសិត-បន្ទាត់ខ្លះពីរឿងប្រទេសជាតិមាតុភូមិ-ពីស្នេហាចំពោះប្រទេសនិងទង់ជាតិ ។

* * * *

## មេរៀនទី ៥២ ពីមាតុភូមិតូចទៅមាតុភូមិធំ

កាលអ្នកនៅពីតូច អ្នកមើលមិនហួសឆ្ងាយពីផ្ទះកំណើតអ្នកទេ ។ ដល់អ្នកទៅរៀនឯសាលា កាលណា ទើបអ្នកស្គាល់ភូមិដែលអ្នកនៅ ។ អ្នកធំឡើងកាលណា ទើបអ្នកស្គាល់មាតុភូមិធំរបស់អ្នក ពោលគឺស្គាល់ស្រុកនគរប្រទេសរបស់អ្នក ។ តាមធម្មតា នៅពេលនោះ មនុស្សមិនភ្លេចភូមិកំណើតខ្លួនឯងទេ, ប៉ុន្តែចំពោះមាតុភូមិធំ មនុស្សត្រូវមានករណីយកិច្ចច្រើនទៀតបំពេញ ។

ក) យើងមានចិត្តប្រតិព័ទ្ធស្មោះស្ម័គ្រនឹងមាតុភូមិតូច ។ ចំណែកឯមាតុភូមិធំ យើងមានចិត្តស្ញប់ស្ញាប់ កាលណាមាតុភូមិធំយើងមានគ្រោះថ្នាក់ ។ យើងស្រឡាញ់មាតុភូមិតូច ប្រៀបដូចកូនក្មេង, យើងស្រឡាញ់មាតុភូមិធំប្រៀបដូចមនុស្សធំ ។ យើងមិនភ្លេចសាប់

ឈាម, ប៉ុន្តែយើងត្រូវគិតដល់បុគ្គលឯទៀតផង, ហើយមុនដំបូងបង្អស់គឺមាតុភូមិរបស់យើង ដែលយើងត្រូវគិតខានមិនបាន ។

ខ) យើងស្រឡាញ់មាតុភូមិធំ គ្មានការខុសគ្នាអ្វីនឹងមាតុភូមិតូចឡើយ, យើងស្រឡាញ់ភូមិយើង ស្រុកកំណើតយើង, ប៉ុន្តែយើងត្រូវដំកល់ទុកឲ្យដាច់ពីមាតុភូមិធំដោយឡែកសិន ។ ផ្ទុយមកវិញកាលបើយើងស្រឡាញ់មាតុភូមិធំ គឺយើងគិតថាយើងស្រឡាញ់មាតុភូមិតូចទាំងឡាយ ដែលនៅក្នុងការៈមាតុភូមិធំ ។

មានអ្វីខ្លះនៅក្នុងមាតុភូមិ? ថាមានទឹកដី, ពីព្រោះតែកាលណាមានមនុស្សមកដណ្តើមដី ឬស្រុកភូមិណាមួយ អ្នកស្រុកទាំងឡាយដែលស្មោះស្ម័គ្រនឹងមាតុភូមិតែងកើតទុក្ខមិនសុខចិត្ត ដូចគេកាត់ដៃឬជើងម្ខាងដែរ, មិនត្រឹមតែប៉ុណ្ណោះទេ មនុស្សនៅលើដីនោះពោលគឺខ្មែរតាំងពីដូនតាដែលស្លាប់ទៅហើយ ទាំងអ្នករស់នៅសព្វថ្ងៃ ទាំងកូនចៅដែលបង្កើតមកទៀតនោះ ត្រូវមានសេចក្តីសាមគ្គីសាមគ្គានឹងគ្នា; អ្នកទាំងនោះត្រូវមានគំនិតនឹងចិត្តតែមួយ ។

ចោទសួរ– មាតុភូមិតូចនិងមាតុភូមិធំខុសគ្នាដូចម្តេច? ត្រូវមានចិត្តប្រុងពេទ្

ដូចម្ដេចចំពោះប្រទេស? អ្វីខ្លះដែលមាននៅក្នុងមាតុភូមិ? ជនអ្នកនៅក្នុងមាតុភូមិត្រូវមានសាមគ្គីសាមគ្គានឹងគ្នាដូចម្ដេច?

## មាតុភូមិពេញលក្ខណៈលុះត្រាតែរដ្ឋមិនបែកខ្ញែក

រដ្ឋមួយៗ បើអ្នកស្រុក•ស្គាល់ច្បាស់ប្រាកដថាជាស្រុករបស់ខ្លួនហើយ មុខជាជាប់ចិត្តស្រឡាញ់ដកប មិនថាក្រមិនថាមាន មិនថាក្ដៅមិនថាត្រជាក់ឡើយ ។ សេចក្ដីស្នេហាដល់ស្រុកកំណើតនេះ គេនឹងឃើញច្បាស់ប្រាកដនៅពេលដែលនឹងចេញពីស្រុកកំណើតៗ ហេតុដូច្នេះបានជាមានខ្មែរច្រើនគ្នា ដែលបានធ្វើដំណើរទៅប្រទេសដទៃ លុះបានឃើញស្រុកគេកាលណា មានសេចក្ដីសរសើរដល់លំអស្រុកគេ ដល់ការបេះធីងរបស់ជាតិគេ ។ល។ ប៉ុន្តែនៅតែមានពាក្យពោលថា ស្រុកគេសប្បាយមែនពិត, ទាស់តែមិនស្រួលដូចស្រុកយើង ។ សេចក្ដីនេះបង្ហាញឲ្យឃើញថា ខ្មែរអ្នកធ្វើដំណើរទាំងនេះ មានចិត្តនឹករឮកមកដល់ស្រុក មានចិត្តជាប់នឹងរបស់នឹងមនុស្សដែលឃើញជាញឹកញយ ធ្លាប់ស្គាល់ពិតប្រាកដ ធ្លាប់ស្គាល់សេចក្ដីសុខទុក្ខ ពោះអាក្រក់ល្អខុសគួរត្រឹមត្រូវយ៉ាង

ណា ក៏នៅឃើញថាល្អដោយយ៉ាងដោយឡែក ៗ ហេតុដូច្នេះ គួរឃើញយល់ដល់ពាក្យបារាំងពោលថា "គួរនៅផ្ទះស្បូវដែលជារបស់ខ្លួន ជាជាងនៅក្នុងវាំង ដែលជាលំនៅរបស់គេ" ៗ

អ្នកសរសេរប្រវត្តិសាស្ត្របារាំងឈ្មោះ «Michelet» សរសេរថា មើលទៅស្រុកបារាំងគ្មានខ្វះត្រង់ណា ៗ

បារាំងនេះពេញចិត្តជាងគេ បំពោះស្រុកគាត់ ដែលមានភាពដូចគ្នាទាំងអស់ ៗ សេចក្តីស្នេហាបែបនេះ កើតមកពីគេស្គាល់ស្រុករបស់គេ ៗ ចាប់តាំងពីមនុស្សក្មេងរហូតដល់មនុស្សចាស់, តាំងពីអ្នកល្ងង់ទៅដល់អ្នកប្រាជ្ញបណ្ឌិត សឹងស្គាល់ស្រុកកំណើតរបស់គេពិតប្រាកដ ៗ ក្មេងៗ ស្គាល់ស្រុកកំណើតដោយឪពុកម្តាយជួយបំភ្លឺ ឬដោយសៀវភៅតែងតម្រូវដូច្នេះ ៗ ពួកមនុស្សចាស់ ទាំងអ្នកល្ងង់ទាំងអ្នកចេះ ស្គាល់ច្បាស់តាំងពីក្មេងមកដោយអ្នកប្រាជ្ញបំភ្លឺ និងសៀវភៅដែលតែងអំពីរឿងរ៉ាវអស់នោះ ៗ

ការស្នេហាមាតុភូមិដែលផុះជាប់ក្នុងចិត្តយើងម្នាក់ៗ មិនមែនជាប់មកដោយសារស្រុកយើងល្អឬអាក្រក់ទេ, ព្រោះថាអ្នកដទៃគេ

ស្គាល់ស្រុកយើងខ្លួនខ្លីលើសយើងទៅទៀតក៏មាន, ប៉ុន្តែគេគ្រាន់តែមានសេចក្តីកោតសរសើរប៉ុណ្ណោះ, ឯត្រង់ជាប់ចិត្តដូចយើងគ្មានទេ ។ ដូចឧទាហរណ៍ខាងក្រោមនេះ ៖

យើងមានសេចក្តីស្នេហាចំពោះម្តាយយើង ខុសគ្នាយ៉ាងខ្លាំងពីការគោរពរាប់អានដោយស្និទ្ធស្នាលចំពោះជនឯទៀត; យើងគោរពម្តាយយើង ខុសគ្នាពីសេចក្តីគោរពចំពោះជនដទៃ ។ ដូច្នេះបានជាគេប្រៀបប្រដូចសេចក្តីស្នេហាចំពោះមាតុភូមិ នឹងសេចក្តីស្នេហាចំពោះឪពុកម្តាយ ។

* * * *

## មេរៀនទី ៥៣ សេចក្តីស្នេហាចំពោះមាតុភូមិ

មាតុភូមិទុកដូចជាគ្រួសារមួយធំ ។ ដូច្នេះយើងរាល់គ្នាមានករណីយកិច្ចនឹងបំពេញមាតុភូមិ ដូចជនម្នាក់ៗ ដែលមានករណីយ-កិច្ចនឹងបំពេញចំពោះគ្រួសារដែរ ។

ស្នេហាមាតុភូមិមានច្រើនយ៉ាង ។ ស្នេហាមាតុភូមិពិតប្រាកដកម្រមានណាស់ ។ គេតែងតែទូន្មានឲ្យស្រឡាញ់មាតុភូមិរបស់ខ្លួន

មិនមែនទូន្មានឱ្យស្អប់មាតុភូមិណាទេ ។ យើងស្រឡាញ់មាតុភូមិយើង, គេក៏ស្រឡាញ់មាតុភូមិរបស់គេដែរ ។ មនុស្សណាមានចិត្តជាមនុស្សធម៌, មនុស្សនោះប្រឹងបេះពន្យល់ឱ្យយល់ហេតុនឹងផល ឥតបង្ខំចិត្តគេឱ្យគេស្រឡាញ់តែមាតុភូមិខ្លួនឡើយ ។ ជនទាំងឡាយកាលបើយល់ហើយរមែងជាប់ចិត្តស្រឡាញ់ ។ ការស្រឡាញ់បែបនេះឋិតថេរជានិច្ច ។ ជួនកាលមាតុភូមិគេប្រសើរជាងមាតុភូមិគេឯទៀតក៏មាន ។ យើងតោងទទួលស្គាល់របស់គេ, ប៉ុន្តែមិនត្រូវក្បត់មាតុភូមិយើងឬបង្អាប់មាតុភូមិយើងទេ ។ បើយើងចង់បានមាតុភូមិយើងឱ្យថ្លៃដូចគេ ត្រូវតែយើងប្រឹងធ្វើការឱ្យមាតុភូមិយើង ។ បើយើងមិនធ្វើក៏មិនកើតដែរ ។

* * * *

## មេរៀនទី ៥៤ សេចក្ដីស្នេហាពិតប្រាកដ

ការស្រឡាញ់មាតុភូមិ មិនមែនពោលក្ដែងៗ ឱ្យតែគេឮនោះទេ; តោងធ្វើការអ្វីមួយ ឱ្យឃើញថាយើងស្រឡាញ់មាតុភូមិពិតប្រាកដ ។ ប៉ុន្តែបើជនណាធ្វើការអ្វីចំពោះមាតុភូមិ ប្រទះលើការលំបាក

ហើយត្រាកចិត្តចោលការនោះទៅវិញ, ជននោះឈ្មោះថាបង្ហាញបុកពាគ្រាន់តែឲ្យគេថាខ្លួនស្រឡាញ់ដែរប៉ុណ្ណោះ ។ សំដីនិយាយហាក់ដូចជាគួរឲ្យទុកចិត្ត, ប៉ុន្តែឥតធ្វើការ, នេះដូចបុរាណពោលថា "រស់តែពាក្យ ត្រគាកស្វាប់ស្អុក" ។

អ្នកដែលស្រឡាញ់មាតុភូមិពិតប្រាកដ មិនមែនជាអ្នកឡូឡាឲ្យគេឮទេ, ច្រើនតែសម្ងំធ្វើការដែលមានប្រយោជន៍ ដល់មនុស្សច្រើនគ្នាតទៅ, ជួនកាលស៊ូខាតប្រយោជន៍ខ្លួនទៀតផង ។

សំដីទទេ ទុកជាគោលការណ៍នៃសេចក្ដីស្នេហាមាតុភូមិ មិនបានឡើយ ។ តោងយើងមើលអំពើដែលធ្វើនោះផង តើខូចប្រយោជន៍យ៉ាងណា ចំរើនយ៉ាងណា ។ ដូច្នេះ ក្នុងការសំគាល់មនុស្ស ត្រូវប្រយ័ត្នមើលឲ្យស្គាល់ច្បាស់ថា មនុស្សដែលប្រកាសថាស្រឡាញ់មាតុភូមិ តើជាអ្នកស្រឡាញ់មាតុភូមិពិតប្រាកដ ឬក៏គ្រាន់តែជាអ្នកអំនួតក្រៅទេ ។

១ – ស្នេហាយល់ពេញទំ គឺស្នេហាដូចយើងស្នេហាសាច់ញាតិសាលោហិត; នៅគ្រាមានទុក្ខ យើងមានចិត្តរំភើបឈឺចាប់

មែនទែន ៗ មានខ្លះអាងថា កំណើតខ្លួនមកបែបណា ក៏រស់នៅបែបនោះ, ម្ល៉ោះហើយក៏មិនរើ.ប់, ច្រើនមានអធ្យាស្រ័យនិយមថាតាមតែបែបណាក៏ដោយចុះ ៗ បើសិនជាយើងគិតតែប្រព្រឹត្តដូច្នេះគ្រប់ៗគ្នា, តើនរណានឹងស្រឡាញ់មាតុភូមិ? ម្យ៉ាងទៀតគោងផងថាអ្វីៗក៏ដោយ ច្រើនកើតឡើងដោយសាររៀនប្រព្រឹត្តធ្វើដែរ. ដូចពាក្យថា "ចេះពីរៀន បានពីរក" ៗ ប្រទេសដទៃកាលពីដើមក៏មិនយល់ការស្នេហាមាតុភូមិប៉ុន្មានដែរ, ប៉ុន្តែដោយហេតុមកពីនាយកស្រុក និងរដ្ឋាភិបាលព្រមទាំងអ្នកស្រុកផង រកផ្លូវទាំងថ្ងៃទាំងយប់បណ្តុះបណ្តាលជាតិគេឡើង ទើបជាតិគេ ក៏ចេះស្រឡាញ់មាតុភូមិដោយយល់ច្បាស់ មិនចាំបាច់គេបង្ខំ ៗ

២–ស្នេហាយល់ពេញទី គឺប្រព្រឹត្តជាល្បើងយល់ មិនធ្វើតាំងងងឹត ៗ យើងស្រឡាញ់មាតុភូមិយើង, យើងនិយមលើកមាតុភូមិយើង, ប៉ុន្តែមិនដល់ទៅបំបាត់បំភ្លេចកិរិយាល្អ របស់មាតុភូមិគេនោះឡើយ ៈ បើយើងគិតឃើញថា មាតុភូមិយើងនៅទាស់នៅខ្វះមិនទាន់សព្វគ្រប់, មានមាតុភូមិដទៃមានកិរិយាល្អជាង គួរឲ្យយើង

គោរពសេរី, យើងត្រូវគោរពសេរីហើយរកផ្លូវកែប្រែមាតុភូមិយើងឲ្យបានល្អដូចគេ ។ ប៉ុន្តែយើងមិនត្រូវតិះដៀលរិះគន់ចំពោះមាតុភូមិគេ ដែលយើងឃើញថាអន់ថយជាងយើងទេ ។

ករណីយកិច្ចចំពោះមាតុភូមិ គឺត្រូវការពារទឹកដីរបស់មាតុភូមិ ។ ឯការការពារនេះ ត្រូវការពារទាំងទឹកទាំងដីដែលត្រូវអន្តរាយនៅមុខទ័ព, ត្រូវដឹងថាក្នុងកិច្ចការពារទឹកដី, យើងមុខជានឹងទទួលគ្រោះថ្នាក់ ឬស្លាប់បង់ជីវិតក៏មាន ។

ពាក្យសួរ–ដែលហៅថាស្រឡាញ់មាតុភូមិនោះតើពលរដ្ឋត្រូវធ្វើដូចម្ដេចខ្លះ? ដូចម្ដេចដែលហៅថាស្នេហាយល់ពេញទីបំពោះប្រទេស ? ចូរអធិប្បាយពីករណីយកិច្ចចំពោះមាតុភូមិ ?

* * * *

## មេរៀនទី៥៥ កម្ពុជា ឫទ្ធិអំណាច

## Le Cambodge. Ses grandeurs.

១–ប្រទេសរបស់យើង គឺកម្ពុជា ។ ហេតុប្រែនជាអនេកដែលយើងជាពលរដ្ឋយ៉ាងក្លាហាន តែងសំគាល់ថាជាប្រទេសខ្ទួនៗ គ្រឿងបរិភោគទំនុកបរិភោគក្នុងប្រទេសយើងក៏សម្បូណ៌ហូរទូលាយៗ

អធិប្បាយថា: ប្រទេសកម្ពុជា កាលសម័យបុរាណ មានរាជធានីនៅនគរវត្ត; តាំងពីសម័យនោះរៀងមក ជាប្រទេសឯករាជ្យមានមហាអំណាចរុងរឿង អាចវាតព្រំប្រទល់ឆ្ងាយទូលំទូលាយ គឺខាងជើងទល់នឹងស្រុកចិន, ខាងកើតទល់នឹងស្រុកចម្ប៉ា, ខាងត្បូងទល់នឹងសមុទ្រ, ខាងលិចទល់នឹងទន្លេមេណាម (ថៃឡង់) នឹងភូមា ។ តាំងពីដើមរៀងមកមិនដែលនៅក្រោមអំណាចប្រទេសណាមួយទេ, ទើបតែមកដល់សតវត្សនេះ ទើបធ្លាក់ទៅជាជោគទាបដុនដាប ដោយមកពីពួកក្សត្រចេះតែដណ្តើមរាជ្យគ្នា បែកសាមគ្គីគ្នា ជាហេតុនាំឲ្យប្រទេសធ្លាក់ទៅក្នុងហីនភាពអាប់ឱនភ័ស ។ អស់ទាំងភស្តុតាងសឹងមានចារឹកទុកជាគោល ដូចជាប្រាសាទនគរវត្តសព្វថ្ងៃនេះ ដែលតាំងចំពាក់កណ្តាលប្រទេស បង្អុលឲ្យឃើញថាព្រំប្រទល់ស្រុកខ្មែរ ពុំមែនតូចដូចសព្វថ្ងៃនេះទេ ។

ប្រទេសកម្ពុជា បើពណ៌នាពីភាគទ្រព្យវិញ ជាប្រទេសសម្បូណ៌សប្បាយដោយវត្ថុគ្រប់យ៉ាង, ជាផែនដីមានទីទាបខ្ពស់ មានទន្លេធំមួយដែលជាសួនយ៉ាងធំ អាចស្រោចស្រប់ក្នុងរដូវទឹកឡើង

ស៊េរីតែគ្រប់ដំបន់ក្នុងប្រទេស  នាំគាំងដីជាតិមកកោយរាយស្រោច ស្រប់ក្នុងទីស្រែចំការចម្ការដំណាំ ៗ

ក្រៅពីរទេះធំមួយនេះ  នៅមានរទេះស្ទឹងបឹងបួតូចៗជាច្រើន, មានរទេះសាបយ៉ាងធំ  ដែលជាមេឃ្លាំងគ្រីជាអាហារខាងទឹកសាប ទីផ្សារកប្រទេសណាមួយក្នុងសកលលោក  ដែលសម្បូណ៌ត្រីទឹក សាបមកប្រៀបផ្ទឹមពុំបាន,  មានកំលល្បីងល្បើយសម្រាប់ធ្វើរបរ កសិកម្ម មានក្លឹទីផ្សារគ្រួជាតិផ្សេង ៗ ដែលជាសម្បត្តិរបស់ប្រទេស ៗ

ចំណែកខាងពាណិជ្ជកម្មក៏ចេញបានគ្រប់ទិស  នៅកាន់បរ-ទេសនានា  តាំងពីផ្នែកទិសខាងជើងនិងខាងលិចរហូតដល់ខាងត្បូង ដូចជាផ្នែកដីខាងកូសាំងស៊ីន  ដែលខ្មែរយើងហៅថាកម្ពុជាក្រោម ដែលជាតិបារាំងសែសបានលើកដីនេះឲ្យទៅយួន  (វៀតណាម) សព្វថ្ងៃនេះ សឹងជាចំណតនាវាបរយ៉ាងល្អ ៗ ត្រូវយើងកុំភ្លេចថា ដែនកូសាំងស៊ីនសព្វថ្ងៃនេះជាទឹកដីរបស់ខ្មែរសុទ្ធៗ  ត្រូវតែនាំគ្នា តាមទារយកមកវិញ ថ្ងៃណាមួយ  ៗ  អំពីពលរដ្ឋរបស់ប្រទេស, ជាតិខ្មែរជាជាតិអ្នកចម្បាំង  មានសេចក្តីស្មូតត្រង់នឹងប្រទេសជាតិ

មាតុភូមិ ជាអ្នកកាន់ព្រះពុទ្ធសាសនា ។ អស់ទាំងជនបរទេសក្នុងសកលលោក សឹងផ្តួលផ្តើមនាំគ្នាមកទស្សនាប្រាសាទនគរវត្ត ដែលជាប្រាសាទល្អយ៉ាងបំផុតក្នុងលោកនេះ ។

ចោទសួរ–ចូរទាញហេតុផលដែលយើងជាពលរដ្ឋខ្មែរត្រូវមាន ចិត្តនៅក្នុងប្រទេសកម្ពុជា ? ចូរអធិប្បាយពីប្រទេសកម្ពុជាសម័យបុរាណនិងសម័យបច្ចុប្បន្ន និងពីកូសាំងស៊ីនកាលដើមជារបស់នរណា ? ម្តេចក៏ឥឡូវទឹកដីនេះធ្លាក់ទៅនៅលើដៃជនដទៃ? ដូច្នេះតើយើងត្រូវគិតដូចម្តេច ?

## ការអាន

## ដូចម្តេចដែលហៅថាប្រទេស

ពាក្យថាប្រទេសនោះ មិនសំដៅចំពោះតែទីវាល ទីព្រៃដីភ្នំ ទន្លេ ស្ទឹង បឹងបួ អស់ទាំងស្រុកជាតិទាំងឡាយរបស់អ្នក ឬដួងស្គរ សម្រាប់កាយរបស់អ្នក ឬចម្រៀងយ៉ាងអន្ទូងអន្ទាច របស់ពួកគង្វាល ប៉ុណ្ណោះទេ, ប្រទេសនោះគឺជាស្រុក និគម ជនបទ និងបណ្តាក្រុង ពលរដ្ឋ ដែលមាននៅក្នុងប្រទេសទាំងប៉ុន្មាននោះទៀត ! ប្រទេស

នោះគឺមានបណ្ដាក្រស្ដ ពោលភាសាដូចគ្នា មានចិត្តថ្លើមឈាមជាប់ ទទួលសុខទុក្ខដូចគ្នាចំពោះប្រទេស គឺជាកត្តិយសរបស់មាតាបិតាយើង គឺជាសិរីភាពរបស់ប្រទេស ៗ ផ្ទៃមេឃដែលយើងមើលទៅឃើញសន្ធឹម, ព្រះអាទិត្យដែលបំភ្លឺយើង, ទន្លេ ស្ទឹង បឹងបួ ដែលហូរស្រោចស្រប់មកលើផែនដីទាំងប៉ុន្មាន, អស់ទាំងព្រៃព្រឹក្សាលតាវល្លិដែលមានម្លប់ត្រឈឹងត្រឈៃ, អស់ទាំងដីដែលមានជីជាតិល្អ ដែលសណ្ដកសន្ធឹងក្រោមបាតជើងយើង, អស់ទាំងនេះហើយដែលហៅថាប្រទេស ៗ ដែលហៅថាប្រទេសនោះ គឺមនុស្សម្នាប្រុសស្រី តូចក្ដី ធំក្ដី មានក្ដី ក្រក្ដី ៗ អ្នកត្រូវស្រឡាញ់គោរពប្រទេសរបស់អ្នកឲ្យណាស់ ត្រូវបំរើប្រទេសជាតិមាតុភូមិរបស់អ្នកឲ្យអស់ពីចិត្ត ដោយស្មោះស្ម័គ្រ ៗ

ចោទសួរ - ដូចម្ដេចដែលហៅថាប្រទេស? ចូរអធិប្បាយឲ្យពិស្ដារដើម្បីឲ្យសិស្សឯទៀតបានយល់ចិត្តផង?

* * * *

# មេរៀនទី ៩៦ គោរពច្បាប់សម្រាប់ប្រទេស

## Respect des Lois

១– មនុស្សក្នុងសង្គម តែងតែមានចិត្តគំនិតអធ្យាស្រ័យយល់ផ្សេងៗគ្នាមិនស្របគ្នាទេ បើនតែគិតទៅតាមទំនើងចិត្តរបស់ខ្លួន ពុំសូវគិតក្រែងដល់សិទ្ធិអ្នកដទៃឡើយ ។

អធិប្បាយថា : សង្គមបែបនេះ នឹងនាំឲ្យប្រទេសជាតិមាតុភូមិធ្លាក់ទៅជាប្រទេសគ្មានរបៀបរៀបរយ, កើតទៅជាចម្បាំងពំងដល់នឹងគ្នា បណ្តាលឲ្យមានទុក្ខក្នុងស្រុកពុំខាន ។ ដូច្នេះ ក្រុមសង្គមទាំងអស់ ត្រូវតែមានបង្កើតច្បាប់របៀបចំឲ្យទៅជាដែនសីមា ដែលមានរាជការធំកាន់កាប់ ដើម្បីការពារប្រជាជនឲ្យបានសេចក្តីសុខក្សេមក្សាន្តរៀបរយក្នុងប្រទេសឡើង ។

២– ច្បាប់សម្រាប់ប្រទេសនីមួយៗ តែងប្រព្រឹត្តទៅតាមកាលៈទេសៈ ។

អធិប្បាយថា : ច្បាប់គ្រប់គ្រងប្រទេស លុះតែឲ្យបណ្តាជនស្គាល់ថាជាច្បាប់ត្រឹមត្រូវមិនផ្ទុយនឹងលទ្ធិសាសនា ដែលពលរដ្ឋ

មានករណីយកិច្ចត្រូវគោរព ។ ច្បាប់នេះពលរដ្ឋទាំងឡាយត្រូវមានករណីយកិច្ចបញ្ជាក់ លុះតែឃើញមានការគោរពរវាងគ្នានឹងគ្នា ទើបអាចមានវិន័យទឹង ។

៣- នៅប្រទេសកម្ពុជាយើងសព្វថ្ងៃ ព្រះករុណាទ្រង់ព្រះរាជ-ទានដាក់ឲ្យទៅជាប្រទេសកាន់លទ្ធិប្រជាធិបតេយ្យ បើកសិទ្ធិឲ្យបណ្ដារាស្ត្រមានអំណាចបោះឆ្នោតរើសដំណាងរាស្ត្រគ្នាឯង ឲ្យជាអ្នកតែងតាំងច្បាប់ ដូចមានពោលក្នុងរដ្ឋធម្មនុញ្ញ ដែលតែងឡើងពីឆ្នាំ ១៩៤៧ ស្រាប់ ។

អធិប្បាយថា : លទ្ធិប្រជាធិបតេយ្យនេះ អាចធ្វើឲ្យបណ្ដារាស្ត្រមានអំណាចស្មើមុខគ្នា ហើយបំពេញករណីយកិច្ចបានដូចគ្នាដោយសេរី ។ ដូច្នេះពលរដ្ឋទាំងឡាយត្រូវចងចាំទុកក្នុងចិត្តហើយត្រូវខិតខំធ្វើការរកស៊ីដើម្បីប្រយោជន៍ដល់ប្រទេសជាតិមាតុភូមិតទៅ ។

៤- សេចក្ដីបញ្ញត្តិទាំងរបៀបរៀបរយ ដែលមាននៅទីសាលារៀន ទុកដូចជាច្បាប់ដែលបង្កើតឡើងសម្រាប់ប្រទេសដែរ ហើយកុលបុត្រទាំងឡាយ ត្រូវតែទម្លាប់ហាត់ប្រតិបត្តិតាម ។

អធិប្បាយថា: យើងត្រូវតែរៀបចំខ្លួនឲ្យទៅជាពលរដ្ឋដ៏សុចរិត មិនត្រូវតាំងខ្លួនជាអ្នកមិនដឹងមិនឮមិនស្គាល់ច្បាប់នោះឡើយ ៗ ដូច្នេះ បើពុំចង់ឲ្យមានការគោះហៅពីចៅក្រមសាលា ដែលជាអ្នកកាន់អំណាចតុលាការ សម្រាប់ផ្ដន្ទាទោសមនុស្សល្មើសនឹងផ្លូវច្បាប់ តោងតែធ្វើខ្លួនឲ្យល្អផុតពីកហុសផ្លូវច្បាប់ទើបបានសេចក្ដីសុខ ៗ

## ភាសិត-បិដ្ឋា

គេនឹងមានសេរីភាពទៅបាន លុះតែគេប្រតិបត្តិទៅតាមច្បាប់ ៗ

បើគ្មានច្បាប់ជាទំនប់ទេ សេរីភាពរបស់មនុស្សនឹងទៅជាស្ទឹង មានខ្សែទឹកកាច ៗ

លទ្ធិប្រជាធិបតេយ្យ ដែលនឹងរស់ជីវិតទៅបាន ព្រោះ អាស្រ័យគុណសម្បត្តិល្អរបស់ពលរដ្ឋ ៗ

ច្បាប់របស់ប្រទេសទាំងអស់ត្រូវប្រកាសឲ្យដឹងទូទៅ ៗ

ចោទសួរ— នឹងទៅជាដូចម្ដេចទៅ ប្រទេសដែលគ្មានរាជការកាន់កាប់ ? របៀបគ្រប់គ្រងប្រទេសនោះ តើដូចម្ដេចខ្លះ ? ករណីយកិច្ចរបស់ពលរដ្ឋចំពោះរាជការ និងច្បាប់ដូចម្ដេចខ្លះ ? ដូចម្ដេចដែលហៅថាលទ្ធិប្រជាធិបតេយ្យ ? ឲ្យសិស្ស ២-៣ នាក់ ឈរឡើងនិយាយរៀបរាប់សាដើមឡើងវិញ ?

# ខ្ញុំសូមសន្យានឹងយក



បញ្ញា
ចិត្ត
ដៃទាំងសងខាង
នឹងកម្លាំងកាយរបស់ខ្ញុំ
បំរើក្រុម, ឃុំ, ស្រុក, ខេត្ត
នឹងប្រទេសរបស់ខ្ញុំ ។

## មេរៀនទី ៤៧ ករណីយកិច្ចចំពោះលោកនីតិ

## ពន្ធដារ រាជការសឹក

## Devoirs civiques.
## L'impôt - Le service militaire

១- ពលរដ្ឋទាំងអស់ត្រូវមានករណីយកិច្ចនឹងបង់ពន្ធ ចូលជាជំនួយដល់រាជការតាមកម្លាំងធនធានរបស់ខ្លួន ទៅតាមបញ្ញត្តិច្បាប់ ដើម្បីទំនុកបម្រុងកិច្ចការសម្រាប់សាធារណជនទាំងឡាយ ដូចជាកងទ័ពជើងគោកជើងទឹក, បន្ទាយការពារ, សាលារៀន, មន្ទីរពេទ្យ, សាលាជំនុំជំរះ, កងក្រវែល, រាជការផ្សេងៗ, ផ្លូវថ្នល់, ព្រែក, ចំណតនាវានៅមាត់សមុទ្រ, គេហដ្ឋានផ្សេងៗ ។

ប្រាក់ដែលរាជការចំណាយនេះ សឹងសុទ្ធតែមានប្រយោជន៍ដល់សាធារណជន ។ ដូច្នេះ ពន្ធដារត្រូវតែពលរដ្ឋទាំងឡាយនាំគ្នាចូលជួយ ។ បើមិនបង់ពន្ធ ទុកដូចជាមានកំហុសចំពោះប្រទេសនឹងចំពោះអ្នកជាប់ពន្ធដូចគ្នា, អ្នកនោះឯង ច្បាប់ហៅថាជាពលរដ្ឋទុច្ចរិត ។

២– ក្រៅពីពន្ធដារផ្សេងៗជាប្រាក់, ពលរដ្ឋនៅមានករណីយកិច្ចមួយទៀត គឺត្រូវបង់ពន្ធឈាម ដែលហៅថាយកឈាមក្រាលផែនដី ដោយការប្រគល់ខ្លួនធ្វើជាទាហានសងគុណផែនដី ។

អធិប្បាយថា: ករណីយកិច្ចរបស់ពិជ័យសង្គ្រាម តម្រូវទៅលើពលរដ្ឋដែលពិនិត្យទៅឃើញថាមានលក្ខណៈគ្រប់គ្រាន់ គ្មានពលរដ្ឋណាមួយអាចនឹងអាក់ខានមិនធ្វើទាហាន ឬក៏កាត់ដៃជើងឲ្យផុតពីករណីយកិច្ចនេះបានឡើយ ។

មនុស្សជំទង់ដែលចេញចាកគ្រួសារ ចាកមិត្រភក្តិ ចាកការងាររបស់ខ្លួនចូលទៅធ្វើទាហាននោះ មិនត្រូវយល់ថាទៅរកសេចក្ដីសប្បាយទេ គឺត្រូវយល់ថាទៅការពារប្រទេស ដើម្បីបង្ក្រាបបច្ចាមិត្រ ធ្វើប្រទេសឲ្យថ្លៃថ្នូរក្សេមក្សាន្តផង ឲ្យកើតគោកទ្រព្យសម្បូណ៌សប្បាយដល់ប្រជាជនទូទៅផង ។ ហេតុនោះត្រូវតែបូជាជីវិតខ្លួនចំពោះប្រទេស ។ ប្រទេសកម្ពុជាយើង គួរតែធ្វើច្បាប់នេះតម្រូវទៅលើពលរដ្ឋទូទៅឲ្យធ្វើទាហាន ដូចជាប្រទេសនានាជិតខាង ទើបគ្រប់លក្ខណៈជាប្រទេសឯករាជ្យ ។

៣- ទាហានត្រូវតែមានករណីយកិច្ច ខំហាត់ឲ្យមានរបៀបរៀបរយ, ឲ្យមានអំណត់អត់ធន់ចេះគោរពច្បាប់ទម្លាប់ខ្លួន ដើម្បីនឹងយកជ័យជំនះក្នុងកាលដែលមានសង្គ្រាមផ្ទុះឡើង ។

អធិប្បាយថា: នៅទីបន្ទាយក៏ដូចជានៅទីសាលារៀនដែរ គ្រាន់តែមានការងារលំបាកជាងសាលារៀនបន្តិចប៉ុណ្ណោះ នឹងចៀសវាងពុំបាន ព្រោះជាការចាំបាច់ ។ នៅពេលសន្តិភាព ទាហានត្រូវបង្ហាញឲ្យឃើញថា ខ្លួនយកចិត្តទុកដាក់គោរពច្បាប់ដោយស្វាមីភក្តិ ទាំងអត់ទ្រាំក្នុងការនឿយហត់ដោយក្លាហាន ។ នៅពេលសង្គ្រាម ទាហានត្រូវការពារតស៊ូចំពោះការលុកលុយទីសមរ-ភូមិដែលខ្លួនត្រូវការពារ ដោយភក្តីភាព ស៊ូស្លាប់ជាជាងចុះចាញ់ ។

៤- ចូរយើងនាំគ្នាខ្ជាប់ពត់ចិត្តទឹងជួយផែនដីដោយការចូលធ្វើទាហាន ដើម្បីថែទាំសាធារណជនទាំងឡាយ, ជួយឧបត្ថម្ភក្នុងការចំរើនភោគទ្រព្យនិងកិច្ចការការប្រទេស ។

អធិប្បាយថា: យើងត្រូវប្រុងប្រៀបរូបកាយខ្លួនប្រាណ បញ្ញានិងចិត្តថ្លើមក្នុងការរស់នៅ ព្រមទាំងបម្រុងខ្លួនទុកជាមុន ដើម្បីនឹង

បំពេញករណីយកិច្ចជាទាហាន ។

ចោទសួរ - ម្ដេចក៏ពលរដ្ឋទាំងអស់គ្នាត្រូវបង់ពន្ធ ? តើជាទោសកំហុសឬបើ ព្រមបង់ពន្ធ? ម្ដេចហៅថាបង់ពន្ធឈាម? អ្នកណាខ្លះត្រូវបង់ពន្ធឈាម? ទាហាននៅ វេលាមានសឹកសង្គ្រាមត្រូវប្រព្រឹត្តដូចម្ដេច? នៅវេលាស្រុកក្សេមក្សាន្តត្រូវប្រព្រឹត្តដូច ម្ដេច? កុមារត្រូវតាំងចិត្តដូចម្ដេចចំពោះការបង់ពន្ធឈាមនឹងកិច្ចការពារការសឹក ។

* * * *

## មេរៀនទី៤៨ ករណីយកិច្ចចំពោះលោកនីតិ ការបោះឆ្នោ

**Devoirs civiques. Le vote.**

អ្នកស្រុកខ្លះដែលពុំទាន់ស្គាល់ច្បាស់ប្រាកដនូវករណីយកិ របស់ខ្លួន ដែលជាអ្នកត្រូវបោះឆ្នោតមានច្រើនគ្នាណាស់ មិនរវ នឹងការបោះឆ្នោតនោះ គឺមិនរវល់បោះឲ្យអ្នកណាទាំងអស់ ។ មនុស្ស បែបនេះ ពាក្យបារាំងហៅ (abstentionistes) ។

ជនអ្នករួមជាតិដែលប្រាកដជាពលរដ្ឋពេញលេញ គោនដ៏ ថា មកពីហេតុអ្វីបានជាត្រូវទទួលការៈបញ្ចេញមតិ (obligation de vote) ។

## ត្រូវតែបញ្ចេញភារៈទទួល

នៅស្រុកខ្លះដូចជា បែលហ្សិក (Belgique) ជាដើម មាន

បញ្ញត្តិបង្ខំឲ្យបណ្ដាជនទៅបោះឆ្នោត ។ ជនណាមិនប្រតិបត្តិ ជននោះត្រូវមានទោស ។ ម្ល៉ោះហើយអ្នកស្រុកដែលមានសិទ្ធិ ះឆ្នោតឬបញ្ចេញមតិ មិនហ៊ានធ្វេសប្រហែសឡើយ ។ ដល់ ពេលវេលាបញ្ចេញមតិ ឬត្រូវបោះឆ្នោត ក៏មម្នាគ្រប់ ៗ គ្នា ទៅ ពេញករណីយកិច្ចនេះ, ក៏ប៉ុន្តែបើគិតតាមត្រឹមត្រូវ មិនគួរបាំបង្ខំ ច្នាះសោះ, គួរតែពលរដ្ឋម្នាក់ ៗ គិតបំពេញកិច្ចនេះដោយខ្លួនឯង ន ត្រូវឲ្យគេបង្ខំ, ត្រូវគិតថា:

ក) ដែលយើងត្រូវធ្វើដូច្នេះ តើមកពីហេតុអ្វី ? គឺយើងគិត ដល់ដម្លៃយើងជាមនុស្ស (dignité personnelle) ។

មនុស្សម្នាក់ ៗ មិនថារាស្ត្រឬមន្ត្រី អ្នកក្រឬអ្នកមាន តែងតែ មានដម្លៃជាមនុស្សដូច ៗ គ្នា ឲ្យតែយើងចេះគិត ចេះស្គាល់ដម្លៃការ នីមួយ ៗ ដែលយើងត្រូវធ្វើ ។ ដូចយ៉ាងអ្នកបោះឆ្នោត គួរដឹងប្រាកដ ថា កិច្ចនេះគឺជាប្រយោជន៍មួយដ៏ប្រសើរ គួរពលរដ្ឋគ្រប់ៗរូបបំពេញ កុំខាន; បើយើងដឹងដូច្នេះហើយ យើងក៏គិតឃើញថា ខ្លួនយើងជា មនុស្សមួយទឹងគេដែរ ទើបគេឲ្យយើងបំពេញករណីយកិច្ចនេះ ។

១) ប៉ុន្តែអ្វីដែលធំបំផុតបណ្ដាលឲ្យយើងបញ្ចេញមតិនេ
នេះមកពីយើងត្រូវគិតប្រយោជន៍ដ៏ឧត្ដមរបស់ប្រទេស (sort de nation) ដែលយើងទទួលបោះឆ្នោតឲ្យបេក្ខជនណាមួយនោះ តែយើងគិតឃើញថាជននោះអាចធ្វើការឲ្យស្រុកបានផលច្រើន, បើយើងមិនរវល់ បោះឆ្នោតឲ្យតែរួបខ្លួន នោះគេថាយើងក្បត់ ដល់មនុស្សរាប់លាននាក់ដែលបានសុខបានទុក្ខដោយសារផង ;

## ប្រទេសបំរើនឬវិនាសក៏មកពីការបោះឆ្នោតនេះដែរ

នៅពេលបោះឆ្នោតតាំងតំណាងរាស្ត្រនីមួយ ៗ អ្នកតំណ
រាស្ត្រនោះជាតំណាងនៃប្រជាជាតិទាំងមូល ពីព្រោះប្រជាជាតិ
ប្រគល់អំណាចឲ្យគេ ៗ ដូច្នេះពលរដ្ឋម្នាក់ ៗ ត្រូវតែបំពេញករ
យកិច្ចរបស់ខ្លួនដែលត្រូវទៅបោះឆ្នោត ៗ មានខ្លះមិនរវល់ ដោយ
ថាមានកិច្ចធុរៈក្នុងគ្រួសារ ៗ មានជនខ្លះទៀតមិនរវល់ ដោយ
ការពិចារណាឲ្យឃើញប្រយោជន៍សោះ ៗ ជនអស់នេះ គេចុ
មនុស្សប្រទូសរ៉ាយចំពោះប្រទេសខ្លួន ៗ

ក្នុងលទ្ធិប្រជាធិបតេយ្យគេធៀបអ្នកបោះឆ្នោតថាដូចជាម

រប្រកបការដោយគន្លងច្បាប់, គេធៀបអ្នកដែលមិនរវល់នឹង ឆ្នោតថាដូចជាមហាក្សត្រដែលដាក់ប្តូរផ្ទេររាជសម្បត្តិ ៗ មនុស្ស បោះឆ្នោត ជាមនុស្សគ្មានវិចារណញ្ញាណត្រឹមត្រង់ ជាមនុស្ស សម្បជញ្ញៈ ជាមនុស្សបើកអំណាចឲ្យពួកទុរជនចូលកាន់រដ្ឋា- ល ៗ ដូច្នេះគេទុកជាមនុស្សឲ្យដៃទៅសត្រូវ ៗ ដោយហេតុនេះ ពលរដ្ឋទាំងឡាយខ្វល់ខ្វាយខំជំនះ លះបង់គំនិតគិតមិនល្អនេះ ញ, ពីព្រោះជាហេតុនាំជនជាតិយើងទៅកាន់ផ្លូវទុក្ខវេទនា ៗ ក្នុងនឹងរើសមនុស្សឲ្យកាន់ដំណែងរដ្ឋាភិបាល យើងជាពលរដ្ឋ ប្រព្រឹត្តដូចម្តេច ?

កិច្ចបោះឆ្នោត ជាកិត្តិយសមួយយ៉ាងប្រសើរ ជាការទទួល ត្រូវយ៉ាងធ្ងន់របស់ពលរដ្ឋ ៗ ដោយហេតុនេះ ពលរដ្ឋដែល ះឆ្នោត ត្រូវតែជ្រើសរើសសាកសួរឲ្យច្បាស់ ពីកិរិយាមារយាទ និតនិងមតិរបស់បេក្ខជនដែលឈរឈ្មោះឲ្យគេបោះឆ្នោត; តើ ក្ខជននោះអាចនឹងមានសម្បទ (aptitude) មានសម្បជញ្ញៈ មាន បក្តីពិតត្រង់នឹងធ្វើការ នឹងដឹកនាំជាតិ ទៅកាន់សេចក្តីសុខ

ចំរើនបានឬដូចម្តេច ?

មុនដំបូងត្រូវពិនិត្យមើលនៅពេលដែលដើរបញ្ចុះបញ្ចូល ពីគ្រ
មានជនខ្លះប្រើផ្លូវបោកឲ្យតែបានឈ្មោះខ្លួនសិន, ដល់កាល
បានអំណាចមកលើដៃ ក៏ភ្លេចពាក្យសន្យាទាំងអស់ឥតគិតប្រយោ
ជន៍ទូទៅដល់ស្រុកសោះៗ មានជនខ្លះមានសមត្ថភាពនឹងធ្វើផលជ
ស្រុក, ប៉ុន្តែបើគិតដល់ប្រយោជន៍របស់ប្រទេស មិនសូវបានផ
ពីព្រោះច្រើនគិតតែប្រយោជន៍របស់ស្រុកដែលរស់នៅប៉ុណ្ណោះ
បានអំណាចហើយ មុខជាឲ្យប្រយោជន៍ដល់ឃុំដល់ស្រុកកំណើ
របស់ខ្លួនតែប៉ុណ្ណោះ ៗ ជនបែបនេះ តើយើងបោះឆ្នោតឲ្យដែរឬ
យើងសុខចិត្តឲ្យអ្នករួមជាតិជាមួយយើងឯទៀត ទទួលគ្រោះថ្នាក់
ឲ្យតែឃុំមួយឬស្រុកយើងមួយបានផលបានសេចក្តីសុខឬ? យើ
ត្រូវគិតដល់ប្រយោជន៍របស់ប្រទេសទាំងមូល មិនត្រូវឆ្ពោះត្រ
ស្រុកមួយៗឡើយ ។

ពលរដ្ឋដែលមានសេចក្តីស្នេហាលើសេរីភាពនិងលើទ្រព្យសម្ប
សាធារណជន ហើយមានសម្បទាល្មមនឹងទទួលដំណែងក្នុងរដ្ឋក